ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

សន្និសីទវិទ្យាសាស្ត្រជាតិអំណាន លើកទី៩

១១ មីនា ២០២៤

# សិក្ខាកថាក្រោមប្រធានបទ៖ «តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌»

ដោយ មី សុវណ្ណា

ព.ស. ២៥៦៧ គ.ស. ២០២៤

# ប្រវត្តិរូបសង្ខេបបេក្ខជន

## ព័ត៌មានទូទៅ

- ឈ្មោះ : មី សុវណ្ណ
- ភេទ : ប្រុស
- ថ្ងៃ ខែ ឆ្នាំកំណើត : ១៦ ធ្នូ ១៩៩០
- ទីកន្លែងកំណើត : ភូមិក្រាំងពញា ឃុំវាលពង់ ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
- ទីលំនៅបច្ចុប្បន្ន : ភូមិដំណាក់ស្នាច់ សង្កាត់វាលពង់ ក្រុងឧដុង្គម៉ែជ័យ ខេត្តកំពង់ស្ពឺ
- កម្រិតជំនាញ : មធ្យមសិក្សាទុតិយភូមិ
- ថ្ងៃ ខែ ឆ្នាំចូលបម្រើការងារ : ០១-១០-២០១៤

## ការសិក្សា

- ២០០៧-២០០៩ : មធ្យមសិក្សាទុតិយភូមិ (វិទ្យាល័យឧដុង្គ កំពង់ស្ពឺ)
- ២០០៩-២០១៣ : បរិញ្ញាបត្រអក្សរសាស្ត្រខ្មែរ (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១៣-២០១៧ : បរិញ្ញាបត្រជាន់ខ្ពស់ភាសាវិទ្យា (សាកលវិទ្យាល័យភូមិន្ទភ្នំពេញ)
- ២០១២-២០១៤ : គរុសិស្សភាសាបារាំង-ខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០១៧-២០១៨ : គរុនិស្សិតកម្រិតឧត្តម អក្សរសាស្ត្រខ្មែរ (វិទ្យាស្ថានជាតិអប់រំ)
- ២០០៩ ជាអតីតជ័យលាភីសិស្សពូកែទូទាំងប្រទេសផ្នែកអក្សរសិល្ប៍ខ្មែរ ឆ្នាំ២០០៩

## អត្តភាពការងារ

- ឆ្នាំ២០១១- ២០២២ : គ្រូបង្រៀនអក្សរសាស្ត្របារាំង-ខ្មែរ នៅវិទ្យាល័យហ៊ុន សែន បាត់ដឹង
- ឆ្នាំ២០២២- បច្ចុប្បន្ន : គ្រូឧទ្ទេសនៅវិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ

## ទំនាក់ទំនងបេក្ខជន


- ទូរស័ព្ទទាក់ទង : ០១៧ ៤២៤ ២៦៣
- តេឡេក្រាម : ០១៥ ៤០៤ ៤៨៣
- អ៊ីម៉េល : **sovannbandit@gmail.com**

## មាតិកា

I- សេចក្តីផ្តើម.......................................................................................................1

II- តួសេចក្តី..........................................................................................................2

II.១- ពន្យល់បច្ចេកសព្ទ.............................................................................................2

II.១.១- បច្ចេកសព្ទ«ព្រះពុទ្ធសាសនា»...............................................................................2

II.១.២- បច្ចេកសព្ទ«ការអប់រំ».........................................................................................2

II.១.៣- បច្ចេកសព្ទ«សីលធម៌».......................................................................................3

II.១.៤- បច្ចេកសព្ទ«ចរិយាធម៌».......................................................................................3

II.២- ពន្យល់ន័យប្រធានបទ.........................................................................................4

II.៣- បកស្រាយប្រធានបទ...........................................................................................5

II.៣.១- តើព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌យ៉ាងដូចម្តេចខ្លះ?......................5

II.៣.២- តើព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ដូចម្តេចខ្លះ?..........................28

II.៣.៣- សំយោគតួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌.............34

II.៤- សរុបខ្លឹមសារ.................................................................................................38

III-បញ្ចប់សេចក្តី......................................................................................................39

# បំណកស្រាយប្រធានបទៈ

# «តួនាទីព្រះពុទ្ធសាសនាក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌»

## I- សេចក្តីផ្តើម

ព្រះពុទ្ធសាសនាគឺជាព្រះធម៌ ពាក្យប្រៀនប្រដៅរបស់ព្រះសម្មាសម្ពុទ្ធដែលបានដឹកនាំប្រជាពុទ្ធបរិស័ទឆ្ពោះទៅរកសេចក្តីសុខសេចក្តីចម្រើន។ យ៉ាងណាមិញ នៅក្នុងប្រទេសកម្ពុជា ព្រះពុទ្ធសាសនាបានរួមចំណែកក្នុងការលើកកម្ពស់ដល់សីលធម៌ និងចរិយាធម៌តាំងពីសម័យបុរាណកាលរហូតមកដល់សម័យបច្ចុប្បន្ននេះ។ យើងបានឃើញថា ព្រះពុទ្ធសាសនាមានអត្ថិភាពជាមួយនឹងប្រជាជនខ្មែរតាំងពីយូរយារណាស់មកហើយ។ វត្តមានព្រះពុទ្ធសាសនាបានប្រតិស្ឋនៅក្នុងប្រទេសកម្ពុជានេះមានការអះអាងខុសៗគ្នាដែលអ្នកខ្លះអះអាងថា ព្រះពុទ្ធសាសនាទំនងជាចូលមកក្នុងប្រទេសកម្ពុជាក្រោយព្រហ្មញ្ញសាសនា ហើយមានឯកសារខ្លះទៀតអះអាងថា ព្រះពុទ្ធសាសនា និងព្រហ្មញ្ញសាសនាអាចចូលមកដំណាលគ្នា ឬប្រហាក់ប្រហែលគ្នាបន្តិចបន្តួចប៉ុណ្ណោះ។ តាមរយៈភស្តុតាងដ៏សំខាន់មួយដែលបានលើកឡើងថា ចាប់ពីចុងឆ្នាំ២០១៧មក មនុស្សម្នាជាច្រើនចាប់អារម្មណ៍យ៉ាងខ្លាំងនឹងសិលាចារឹកមួយផ្ទាំងនៅវត្តគិរីស្តេចគង់ដែលឃើញមានចារឹកពាក្យថា«សុវណ្ណភូមិ»[1]។ វត្តគិរីស្តេចគង់ ហៅវត្តបឹងដែលតាមឯកសារចាស់ៗបញ្ជាក់ថាមានឈ្មោះជា អង្គប្រាសាទទន្លេយ៉ន ស្ថិតនៅភូមិត្រពាំងខ្ទុំ ឃុំស្វាយចចិប ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ។ ទីតាំងវត្តនេះសាងសង់នៅលើទីទួលប្រាសាទបុរាណក្នុងសម័យមុនអង្គរ មានគូទឹកព័ទ្ធជុំវិញ។ តាមប្រភពឯកសារសិលាចារឹកដ៏សំខាន់នេះ យើងអាចអះអាងថាដែនដីសុវណ្ណភូមិគ្មានសំដៅដែនដីឯណាក្រៅពីប្រទេសកម្ពុជានេះឡើយ។ ការរកឃើញសិលាចារឹកដ៏មានសារៈសំខាន់នេះធ្វើឱ្យប្រវត្តិវិទូសន្និដ្ឋានថា សុវណ្ណភូមិ គឺសំដៅលើស្រុកខ្មែរនេះតែម្តងដែលគ្មាននរណាម្នាក់មកបដិសេធបានឡើយ។

តើព្រះពុទ្ធសាសនាមានតួនាទីក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌យ៉ាងដូចម្តេចខ្លះ? នៅក្នុងប្រទេសកម្ពុជាវិញ តើព្រះពុទ្ធសាសនានេះមានឥទ្ធិពលយ៉ាងដូចម្តេចខ្លះដែរ?

---

[1] https://ams.com.kh/khmercivilization/detail/3033

## II- តួសេចក្តី

### II.១- ពន្យល់បច្ចេកសព្ទ

### II.១.១- បច្ចេកសព្ទ«ព្រះពុទ្ធសាសនា»

តាមវចនានុក្រមដែលផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ និងរាជបណ្ឌិត្យសភាកម្ពុជា បានពន្យល់ពាក្យ «ព្រះពុទ្ធ ឬពុទ្ធ»ដូចនេះថា៖ ពុទ្ធ [ពុត] (សំ.បា.) ន. លោកអ្នកត្រាស់ដឹងធម៌ដែលកំបាំងដូចយ៉ាងអរិយសច្ច ៤ជាដើម រហូតដល់មគ្គផលនិព្វាន ឬលោកអ្នកភ្ញាក់រឭក គឺមានសតិសម្បជញ្ញៈសព្វកាល ឬលោកអ្នករីកពេញទីដូចជាផ្កាឈូកដែលរីកគ្រប់ស្រទាប់គឺមានព្រះហឫទ័យរីកដោយអំណាចនៃបរិសុទ្ធិ ព្រោះកម្ចាត់កិលេសអស់ហើយ (ព្រះសម្មាសម្ពុទ្ធ) : ព្រះពុទ្ធ, ព្រះពុទ្ធជាបរមគ្រូ, ព្រះពុទ្ធជាម្ចាស់។ល។

បើតាមវចនានុក្រមខ្មែរ «សាសនា» មកពីពាក្យ «សាសន» ដែលមានន័យថា ពាក្យបណ្តាំ ពាក្យផ្តាំផ្ញើ ពាក្យប្រៀនប្រដៅ ការប្រៀនប្រដៅ សាសនា លទ្ធិ ពាក្យបង្គាប់ ការបង្គាប់បញ្ជា ដំណឹង សំបុត្រ ពាក្យប្រកាស ការប្រកាសប្រាប់ ការជឿស្តាប់ ការដាក់ទណ្ឌកម្ម ការផ្ចាលទោស ការកែសម្រួល ការគ្រប់គ្រង ការត្រួតត្រា[2]។

តាមន័យជាតិសព្ទខាងលើនេះ «ព្រះពុទ្ធសាសនា» បានន័យសេចក្តីថាគឺជាឱវាទ ឬពាក្យអប់រំទូន្មានប្រៀនប្រដៅរបស់ព្រះពុទ្ធអង្គព្រះសម្មាសម្ពុទ្ធដែលព្រះអង្គជាអ្នកត្រាស់ដឹងធម៌ដ៏ប្រសើរក្រៃលែង។

### II.១.២- បច្ចេកសព្ទ«ការអប់រំ»

តាមវចនានុក្រមខ្មែរពាក្យថា «អប់រំ» ប្រើជាពាក្យប្រៀបប្រដូចសំដៅដល់ន័យថាហាត់ចិត្ត, បង្វឹកចិត្ត; ដួសដុលចំពោះវិជ្ជាឬកិរិយាមារយាទ, ហ្វឹកហាត់ឱ្យស្ទាត់ជំនាញជាងមុន, កែឱ្យបានល្អប្រពៃជាងមុនជាលំដាប់; ខំប្រឹងបំពេញឧបនិស្ស័យឱ្យបរិបូណ៌, ខំកសាងសន្សំបុណ្យកុសលរក្សាទុកពុំឱ្យមានហ្មង, មិនឱ្យមានថ្នាំងថ្នាក់; បន្ទុំបារមី: ព្រះបរមពោធិសត្វបានអប់រំបន្ទុំបារមីអស់កាលយូរអង្វែង។ ហើយក៏មានសេចក្តីពន្យល់ន័យមួយទៀតថា បង្រៀន ប្រៀនប្រដៅ ឬបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញា និងសីល

---

[2] ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ បោះពុម្ពគ្រាទី៥ ឆ្នាំ១៩៦៧

ធម៌តាមគ្រប់សកម្មភាពដើម្បីទទួលបានចំណេះដឹង ជំនាញ សមត្ថភាព និងគុណតម្លៃ ហើយក្លាយខ្លួនជាបុគ្គលល្អនិងមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ ប្រទេសជាតិ និងមនុស្សជាតិ[3]។

ដូចនេះការអប់រំគឺជាកិច្ចដំណើរការអភិវឌ្ឍការសិក្សា ឬការបណ្តុះបណ្តាលកាយសម្បទា សតិបញ្ញា និងសីលធម៌តាមរយៈគ្រប់សកម្មភាពអប់រំ។ ការធ្វើឱ្យអ្នកសិក្សាទទួលបាននូវសំណុំចំណេះដឹង ជំនាញ សមត្ថភាព និងតម្លៃ។ ការធ្វើឱ្យមនុស្សក្លាយជាបុគ្គលល្អដែលមានប្រយោជន៍សម្រាប់ខ្លួនឯង គ្រួសារ សហគមន៍ សមាគម ប្រទេសជាតិ និងពិភពលោកទាំងមូល។

### II.១.៣- **បច្ចេកសព្ទ«សីលធម៌»**

### II.១.៣.១- **តាមន័យជាតិសព្ទ**

-**សីលធម៌** មកពីពាក្យថា «សីល» និង«ធម៌» ដែល«សីល»មានន័យថា [4]វិរតិចេតនាដែលវៀរចាកអំពើអាក្រក់, ការកាន់ឬប្រព្រឹត្តល្អដោយកាយវាចា, ការមិនប្រព្រឹត្តកន្លងសិក្ខាបទឬវិនយប្បញ្ញត្តិ(ព.ពុ.)។ រីឯពាក្យ «ធម៌»បានន័យថា [5]សភាវៈដែលទ្រទ្រង់សត្វលោកគឺបុណ្យ, បាប, សុចរិត, ទុច្ចរិត។ ពាក្យនេះខ្មែរយើងធ្លាប់ប្រើជាធម្មតាមកគឺសំដៅយកពាក្យឱវាទរបស់ព្រះពុទ្ធ និងអត្ថបទទូទៅដែលទាក់ទងដោយពុទ្ធសាសនា។ ស្របតាមន័យពន្យល់ខាងលើនេះ«សីលធម៌» បានន័យថា សេចក្តីល្អ ឬសភាវៈដែលទ្រទ្រង់នូវសេចក្តីល្អទាំងឡាយដោយកាយ វាចា ចិត្ត។

### II.១.៣.២- **តាមន័យទស្សនៈ**

ក្នុងការរស់នៅមនុស្សត្រូវមានសីលធម៌ប្រាំយ៉ាងគឺ[6]៖

+**សីលធម៌ផ្ទាល់ខ្លួន៖** ដឹងខុសដឹងត្រូវ ល្អអាក្រក់ ក្លាហាន ហ៊ានទទួលខុសត្រូវលើអំពើរបស់ខ្លួន តាំងជាម្ចាស់នៃចិត្តរបស់ខ្លួនបាន។

---

[3] ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា បោះពុម្ពគ្រាទី១ ឆ្នាំ២០២៣

[4] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត , ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧

[5] វចនានុក្រមខ្មែរ សម្តេចព្រះសង្ឃរាជ ជួន ណាត , ការផ្សាយរបស់វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧

[6] https://www.khsearch.com/qna/14505

+**សីលធម៌ក្នុងគ្រួសារ៖** ស្គាល់នូវកាតព្វកិច្ចរបស់ខ្លួនជាឪពុកម្ដាយ។ ចិញ្ចឹមកូនមិនគិតពីការតបគុណវិញ ធ្វើឱ្យមានភាពសុខដុម។ ស្រឡាញ់ និងឧបត្ថម្ភកូនស្មើៗគ្នា អប់រំកូនចៅជាពលរដ្ឋល្អ។

+**សីលធម៌ក្នុងវិជ្ជាជីវៈ៖** មានមនសិការក្នុងការងាររកតាមសមត្ថភាពនិងតាមសម្មាជីវៈ មិនរំលោភលើអ្នកតូចជាងខ្លួន មិនរំលោភធ្វើការហួសកម្លាំងនាំឱ្យខូចសុខភាព។

+**សីលធម៌ក្នុងសង្គម៖** មានសាមគ្គីភាពល្អ មិនបង្កទំនាស់ គោរពសិទ្ធិមនុស្ស ស្រឡាញ់យុត្តិធម៌ ស្រឡាញ់មនុស្សទូទៅ ទទួលស្គាល់ទុក្ខវេទនាអ្នកដទៃ។

+**សីលធម៌ពិភពលោក៖** មានទំនាក់ទំនងល្អជាមួយបរទេស និងមិនប្រកាន់ជាតិសាសន៍។

ដូចនេះ សីលធម៌ជាគុណតម្លៃដ៏ថ្លៃថ្លារបស់មនុស្សជាតិជាគ្រឿងអលង្ការមិនអាចកាត់ថ្លៃបានដែលបំពាក់ទៅលើចរិតលក្ខណៈនៃបុគ្គលម្នាក់ៗ។ ជាមនុស្សដែលមានសេចក្ដីថ្លៃថ្នូរត្រូវប្រកាន់ខ្ជាប់ឱ្យបាននូវសីលធម៌ និងចរិយាធម៌ដ៏ល្អប្រពៃ ទើបអាចរស់នៅប្រកបដោយសេចក្ដីសុខសុភមង្គល។

### II.**១.៤- បច្ចេកសព្ទ«ចរិយាធម៌»**

តាមវចនានុក្រមបានពន្យល់ពាក្យថា ចរិយា ដូចជា ចរិយា [ចៈ-រ៉ិ-យ៉ា] (បា.សំ. ចយ៌ា) ន. ការប្រព្រឹត្ត; សំណាង, ព្រេង, ព្រេងសំណាង : អ្នកហ្នឹងមានចរិយាល្អណាស់។ រីឯពាក្យថា «ធម៌»វិញមានសេចក្ដីពន្យល់ដូចជា៖ ធម៌ [ធ័រ] (បា.; សំ. ធម្ម)ន. សភាវៈដែលទ្រទ្រង់សត្វលោក គឺបុណ្យ, បាប, សុចរិត, ទុច្ចរិត។ល។ ពាក្យនេះ ខ្មែរយើងធ្លាប់ប្រើជាធម្មតាមក គឺសំដៅយកពាក្យឱវាទរបស់ព្រះពុទ្ធ និងអត្ថបទទូទៅដែលទាក់ទងដោយពុទ្ធសាសនា[7]។ ដូចនេះ ចរិយាធម៌ បានន័យសេចក្ដីថា ជាសភាវៈដែលទ្រទ្រង់នូវការប្រព្រឹត្តដ៏ល្អប្រពៃ ឬជាធម៌អប់រំឱ្យប្រកាន់តែសេចក្ដីល្អដោយកាយ វាចា ចិត្តជាដើម។

## II.**២- ពន្យល់ន័យប្រធានបទ**

ឆ្លងតាមសេចក្ដីពន្យល់ខាងលើនេះ ប្រធានបទទាំងមូលចង់ឱ្យយើងស្រាយបំភ្លឺស្ដីពីតួនាទីព្រះពុទ្ធសាសនាក្នុងជំរុញដល់ការអប់រំទូន្មានប្រៀនប្រដៅដឹកនាំឱ្យមនុស្សសាងតែអំពើល្អ សេចក្ដីល្អ និងចរិយា

[7] ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា បោះពុម្ពគ្រាទី១ ឆ្នាំ២០២៣

មារយាទឱ្យបានល្អប្រពៃនៅក្នុងសង្គម។ ជាពិសេសនៅក្នុងប្រទេសកម្ពុជាដែលជាប្រទេសប្រកាន់យក មាគ៌ាព្រះពុទ្ធសាសនាជាគោល ដោយបានចែងក្នុងបាវចនាជាតិថា«ជាតិ សាសនា ព្រះមហាក្សត្រ»។

## II.៣- **បកស្រាយប្រធានបទ**

### II.៣.១- **តើព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌យ៉ាងដូចម្ដេចខ្លះ?**

ព្រះពុទ្ធសាសនាបានដើរតួនាទីសំខាន់ណាស់នៅក្នុងសង្គមខ្មែរតាំងពីបុរាណកាលរៀងមករហូត ដល់បច្ចុប្បន្ន។ យ៉ាងណាមិញ សាសនានេះបានអប់រំសីលធម៌សង្គមតាមរយៈគោលទ្រឹស្តីរបស់ខ្លួនដូចជា ឱ្យមនុស្សមានហិរិ និងឱត្តប្បៈ។ ពោលគឺសេចក្តីខ្មាសអៀនបាប និងខ្លើមអំពើបាប។

### **ក- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌បុគ្គល**

អំពើល្អ១០យ៉ាងក្នុងការអប់រំសីលធម៌ត្រូវបានព្រះពុទ្ធចាត់ទុកថា ជាគោលការណ៍គ្រឹះ ឬជាឫស គល់នៃធម៌ទាំងឡាយនៃព្រះពុទ្ធសាសនាក្នុងការស្វែងរកសុខសន្តិភាព សុវត្ថិភាព សេចក្តីថ្លៃថ្នូរ កិត្តិយស និងការអភិវឌ្ឍដល់បុគ្គលខ្លួនឯង គ្រួសារ និងសង្គមជាតិទាំងមូល។ អំពើល្អទាំង១០ប្រការនោះគឺៈ

#### **ក.១- អំពើប្រព្រឹត្តល្អដោយកាយ៣ (កាយសុចរិត)**

- ការវៀរចាកអំពើកាប់សម្លាប់ មនុស្ស ឬសត្វមានជីវិតគឺមិនបៀតបៀន មិនធ្វើទុក្ខទោស មិនធ្វើ បាបដោយឥតមេត្តា មិនវាយសំពងដោយព្រនង់ មិនកាប់សម្លាប់ប្រហារបាញ់ចាក់ដោយសាស្ត្រាវុធធ្វើឱ្យ ជីវិតបង់។

-ការមិនកេងបន្លំយកទ្រព្យសម្បត្តិរបស់អ្នកដទៃ ឬក៏ប្រើឱ្យអ្នកដទៃលបលួចលាក់ឆក់ដណ្ដើម ដោយកាយមួយ។

-ការមិនប្រព្រឹត្តខុសក្នុងកាម មិនប្រព្រឹត្តទៅលើប្តី ឬប្រពន្ធអ្នកដទៃដែលគេហួងហែងរក្សា និងធ្វើ ឱ្យគេអាប់កិត្តិយសកេរ្តិ៍ឈ្មោះកើតសេចក្តីអៀនខ្មាសមួយ។

#### **ក.២- អំពើប្រព្រឹត្តល្អដោយវាចា៤ (វចីសុចរិត)**

-វៀរចាកនូវការមិនពោលពាក្យកុហកបោកប្រាស់បំភ័ន្តភ្នែកអ្នកដទៃ។

-ការមិនពោលនូវពាក្យញុះញង់ បំបែកបំបាក់អ្នកដទៃ។

-ការនិយាយតែពាក្យផ្អែមល្ហែមទន់ភ្លន់ពីរោះដែលជាទីគាប់ត្រចៀក ត្រូវចិត្តនៃអ្នកដទៃគឺការមិននិយាយទ្រគោះបោះបោកចាក់ដោតដល់អ្នកដទៃ។

-ការនិយាយអំពីប្រយោជន៍ និងសេចក្តីចម្រើនទាំងពីរប្រការគឺផ្លូវលោកមួយ ផ្លូវធម៌មួយ មិននិយាយពោលពាក្យរោយរាយឥតប្រយោជន៍។

ទាំងនេះព្រះសម្មាសម្ពុទ្ធបានចាត់ទុកថា ការនិយាយត្រូវ (សម្មាវាចា) ។ ការនិយាយត្រូវនេះជាកាំជណ្តើរមួយទៀតឈានឡើងទៅកាន់ការប្រតិបត្តិដើម្បីគ្រប់គ្រងរក្សាខ្លួនឯង។

### ក.៣- អំពើប្រព្រឹត្តល្អដោយចិត្ត៣ (មនោសុចរិត)

-មិនតាំងចិត្តគិតសម្លឹងរំពៃយកទ្រព្យអ្នកដទៃមកជាទ្រព្យរបស់ខ្លួន។ គំនិតប្រកបដោយសេចក្តីសន្តោស ត្រេកអរតាមមានតាមបាន គំនិតប្រកបដោយសេចក្តីខ្មាសបាប គំនិតលះបង់អំពើចង់បានឥតខ្មាស គំនិតស្មោះត្រង់ មិនត្រូវការទ្រព្យសម្បត្តិគេមកធ្វើជាទ្រព្យរបស់ខ្លួន។ តម្រិះត្រូវ (សម្មាសង្កប្បៈ) គឺតម្រិះមិនព្យាបាទអ្នកដទៃ មិនបៀតបៀនអ្នកដទៃ មិនជក់ត្រាំក្នុងកាម។

-មិនចងគំនុំគុំកួនធ្វើឱ្យអ្នកដទៃវិនាសនិងការមិនបៀតបៀនអ្នកដទៃគឺតម្រិះត្រូវ(សម្មាសង្កប្បៈ)។ គំនិតប្រកបដោយមេត្តាគឺស្រឡាញ់រាប់អានសត្វទូទៅ ដូចជាមាតាស្រឡាញ់បុត្រមិនបានព្យាបាទដល់ជនមួយណាឡើយប្រកបដោយករុណាសេចក្តីអាណិតអាសូរចំពោះសត្វទូទៅដែលមានសេចក្តីទុក្ខ ចង់ឱ្យសត្វបានរួចផុតអំពីសេចក្តីទុក្ខ។

-សេចក្តីយល់ឃើញត្រូវ (សម្មាទិដ្ឋិ) គឺឃើញថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាប។ ទស្សនៈត្រូវពិត ភាពសន្សំមានទស្សនៈខុសត្រឹមតែជាសេចក្តីគិតឃើញទៅលើផ្លូវខុសនីមួយៗ។ បុគ្គលគប្បីដឹងដល់សេចក្តីផ្សេងៗនៅក្នុងចន្លោះនៃសេចក្តីស្ថិតស្ថេរ និងសេចក្តីមិនស្ថិតស្ថេរ។

សរុបមក ព្រះពុទ្ធសាសនាមានតួនាទីអប់រំបុគ្គលឱ្យសាងតែសេចក្តីល្អគ្រប់បែបយ៉ាងដោយកាយវាចាចិត្ត ហើយលះឱ្យឆ្ងាយពីបាបធម៌នានា។ ជាមនុស្សដែលមានការអប់រំកាយ វាចា ចិត្តបានល្អហើយរាប់ថាជាមនុស្សល្អខ្លាំងណាស់។ ពីព្រោះថា ការចេះអប់រំខ្លួនឱ្យបានល្អជាការទូន្មានខ្លួនបានដោយកម្រ ប៉ុន្តែមិនមែនថាធ្វើមិនបាននោះទេ។ វីរជននៅក្នុងលោកសុទ្ធតែជាមនុស្សឈ្នះខ្លួនឯង ទើបអាចក្លាយជាគំរូជននៅលើសាកលលោកយើងនេះមានព្រះពុទ្ធអង្គជាគំរូជាដើម។

## ខ- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌ក្នុងគ្រួសារ

ព្រះពុទ្ធសាសនាបានជួយអប់រំសីលធម៌នៅក្នុងគ្រួសារឱ្យចេះស្រឡាញ់គ្នាក្នុងគ្រួសារ ឱ្យស្គាល់តួនាទីគ្នានៅក្នុងគ្រួសារ។

ព្រះពុទ្ធសាសនាបានជួយអប់រំសីលធម៌ក្នុងគ្រួសារក្នុងគោលបំណងឱ្យគ្រួសារបានសេចក្ដីសុខ ដ្បិតថាគ្រួសារជាកោសិកានៃសង្គម។ ប្រសិនបើគ្រួសារមានសុភមង្គល នោះសង្គមជាតិក៏បានសេចក្ដីសុខទៅតាមនោះផងដែរ។ ផ្ទុយមកវិញ ប្រសិនបើគ្រួសារណាមិនមានសេចក្ដីសុខ ជួបតែអពមង្គល នោះនឹងញ៉ាំងឱ្យជីវិតងងឹតអាប់អួពន់ពេកក្រៃ។ ការងារទាំងឡាយមិនមានភាពរលូនល្អឡើយ ដោយសារតែមានបញ្ហាក្នុងគ្រួសារ។ នៅក្នុងគ្រួសារ បើប្ដីប្រពន្ធមិនចុះសម្រុងគ្នា នោះបង្កផលប៉ះពាល់ដល់កូនចៅស្រករក្រោយដែលរស់នៅអាស្រ័យលើឪពុកម្ដាយ។ មាគ៌ាព្រះពុទ្ធសាសនាបានអប់រំឱ្យប្ដីប្រពន្ធមានធម៌សង្គ្រោះដល់គ្នានឹងគ្នាជាសង្គហធម៌ដ៏ប្រសើរ។ ប្ដីត្រូវមានធម៌សង្គ្រោះដល់ភរិយា៥ប្រការដូចជា ភក្ដីភាពដល់ភរិយា ប្រឹងប្រែងរកទ្រព្យចិញ្ចឹមគ្រួសារ និងរកគ្រឿងអលង្ការឱ្យភរិយា។ រីឯប្រពន្ធវិញក៏ត្រូវមានធម៌សង្គ្រោះដល់ប្រពន្ធដោយធម៌៥ប្រការដែរដូចជា ស្រឡាញ់ប្ដីគោរពប្ដី រាប់អានគ្រួសារខាងប្ដី និងរក្សាទ្រព្យសម្បត្តិឱ្យគង់វង្ស។ ប្រការទាំងអស់នេះជាគុណតម្លៃមួយដែលព្រះពុទ្ធទ្រង់បញ្ញត្តិឱ្យគូស្វាមីភរិយាស្គាល់ពីតួនាទីរបស់ខ្លួន។

រីឯភរិយាត្រូវមានសង្គហធម៌៥យ៉ាងដល់ស្វាមីវិញដែរដូចជា ចាត់ចែងផ្ទះសម្បែង សង្គ្រោះញាតិខាងប្ដី ថែរក្សាទ្រព្យសម្បត្តិឱ្យបានគង់វង្ស មិនប្រព្រឹត្តកន្លងចិត្តស្វាមី និងឈ្លាសវៃក្នុងការងារជាដើម។ នេះជាសីលធម៌នៃភារៈប្រពន្ធដែលគប្បីប្រកាន់យក។ កាលណាក្នុងគ្រួសារមានសីលធម៌ទាំងអស់នេះ នោះនាំឱ្យសង្គមគ្រួសារមានសុភមង្គល។ បើនិយាយពីឪពុកម្ដាយវិញ នៅក្នុងគ្រួសារក៏ត្រូវមានធម៌សង្គ្រោះដល់កូនប្រុសស្រីវិញដែរដូចជា ឪពុកម្ដាយហាមកូនឱ្យចៀសឆ្ងាយពីអបាយ ឱ្យប្រព្រឹត្តតែអំពើល្អ ឱ្យកូនសិក្សារៀនសូត្រ រៀបចំគូស្រករឱ្យកូន និងចែកទ្រព្យសម្បត្តិដល់កូនជាដើម។ ចំណែកឯកូនប្រុសស្រីក៏មានភារៈមើលថែដើរតាមពុទ្ធោវាទដោយកូនៗត្រូវមានសង្គហធម៌៥យ៉ាងតបស្នងដល់លោកអ្នកមានគុណវិញដែរ។

ជាមួយគ្នានេះផងដែរ ព្រះពុទ្ធសាសនាទ្រង់ណែនាំឱ្យប្រព្រឹត្តនូវធម៌សង្គ្រោះដល់ខ្ញុំបម្រើប្រុសស្រីដោយធម៌៥ប្រការដូចជា ចាត់ចែងការងារឱ្យសមដល់កម្លាំងកាយ ឱ្យប្រាក់រង្វាន់បានសមស្រប ព្យាបាលជំងឺជូនដល់កម្មកររបស់ខ្លួន ចែកភោជនទៅតាមការគួរ និងបើកឱ្យសប្បាយក្នុងការគួរដូចជាបុណ្យទានជា

ដើម។ រីឯខ្ញុំបម្រើវិញក៏ត្រូវមានធម៌សង្គ្រោះដល់ចៅហ្វាយវិញដែរដូចជាក្រោកឡើងធ្វើការដោយភាពស្មោះស្ម័គ្រត្រូវធ្វើការងារឱ្យដល់ទីបញ្ចប់ មានចិត្តទៀងត្រង់ធ្វើការដោយយកចិត្តទុកដាក់និងនាំយកសេចក្តីល្អរបស់ចៅហ្វាយទៅពោលសរសើរក្នុងទីដទៃ។

សរុបមក ព្រះពុទ្ធសាសនាបានជួយលើកកម្ពស់សីលធម៌ក្នុងគ្រួសារឱ្យស្ថិតក្នុងគន្លងនៃសេចក្តីល្អ និងប្រកបដោយសុភមង្គល។

## គ- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌ក្នុងសង្គមជាតិ

ព្រះពុទ្ធសាសនាបានជួយអប់រំផ្នែកចរិយាសាស្ត្រខ្មែរឱ្យប្រព្រឹត្តតែសេចក្តីល្អគ្រប់ប្រការ។ នៅត្រង់នេះ ការអប់រំបានជួយឱ្យមនុស្សមានការរីកចម្រើន ការលូតលាស់ផ្នែកស្មារតី ឱ្យការប្រព្រឹត្តបានល្អ។ ព្រះពុទ្ធសាសនាបានអប់រំតម្រែតម្រង់មនុស្សឱ្យមានការគិតគូរពិចារណាគ្រប់ជំនាញជីវិត ឱ្យមានភាពសុខដុមជីវិត និងមានស្មារតីភ្ញាក់រឭក។

ប្រសិនបើយើងមើលក្នុងសង្គម តាមរយៈព្រះសង្ឃពុទ្ធសាសនាបានជួយអប់រំដល់សិស្សានុសិស្សនិស្សិត លោកគ្រូអ្នកគ្រូដើម្បីឱ្យប្រិតប្រៀនអត្តចរិត ចេះគោរពវិន័យសាលា ចៀសវាងឱ្យឆ្ងាយពីគ្រឿងញៀន និងដោះស្រាយរាល់ឧបសគ្គប្រឈម។ នៅកម្ពុជា យើងឃើញថាព្រះសង្ឃបានចូលរួមអប់រំសិស្សនិស្សិតឱ្យប្រឹងប្រែងរៀនសូត្រចៀសវាងឱ្យឆ្ងាយពីអបាយមុខគ្រប់ប្រការ និងប្រកបដោយមេត្តា ករុណា មុទិតា និងឧបេក្ខា។ យើងបានឃើញថា នៅតាមសាលានៅពេលបើកបវេសនកាល កៀកចូលឆ្នាំខ្មែរ ឬឱកាសណាមួយរមែងនិមន្តព្រះសង្ឃចូលរួមសម្តែងធម្មទេសនាដល់សាលាទាំងមូល។ សិស្សានុសិស្សយើងទទួលបានការឱ្យពរជ័យពីព្រះសង្ឃផង និងបានត្រងត្រាប់ពុទ្ធោវាទផងដែរ។ ជាមួយគ្នានេះ កម្មវិធីព្រះពុទ្ធសាសនាដែលបានអប់រំចរិយាធម៌ឱ្យស្គាល់គុណមាតាបិតា គុណគ្រូបាអាចារ្យដែលធ្វើឱ្យយើងស្គាល់ពីតម្លៃដ៏ថ្លៃថ្លារបស់អ្នកមានគុណ។ ព្រះពុទ្ធឱវាទជាឃ្លាំងទ្រព្យដ៏មហិមាដល់ប្រជានុរាស្ត្រទូទៅ។

ព្រះពុទ្ធសាសនាជួយទ្រទ្រង់ដល់ការរស់នៅរបស់ប្រជានុរាស្ត្រខ្មែរ ផ្សារភ្ជាប់ជីវភាពពិតៗជាមួយនឹងមនុស្សខ្មែរ។ ជាការកត់សម្គាល់ ទ្រឹស្តីគោលនៃព្រះពុទ្ធសាសនាបានជួយដល់ផ្នត់គំនិតនៃមនុស្ស ឱ្យមនុស្សដើរទៅរកផ្លូវត្រឹមត្រូវមានមេត្តាករុណា មុទិតា និងឧបេក្ខា។ ដូចនេះព្រះអង្គបានប្រដៅមនុស្សឱ្យចេះគោរពសិទ្ធិមនុស្សដូចគ្នា កុំបីមានសេចក្តីប្រមាទ។

## គ.១-ការអប់រំសីលធម៌នៅតាមសាលារៀន

ជាការពិតណាស់ សីលធម៌ជាតម្លៃដ៏ថ្លៃមិនអាចខ្វះបានឡើយ។ កាលណាកម្មវិធីព្រះពុទ្ធសាសនាបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សាបានជួយឱ្យយុវជនមានការយល់ដឹងបន្ថែម សិក្សាបន្ថែម យល់ដឹងបន្ថែមពីមាគ៌ាដ៏ល្អរបស់ព្រះសាស្តា។ ជាពិសេសសិស្សានុសិស្សតាំងពីថ្នាក់មត្តេយ្យសិក្សារហូតដល់វិទ្យាល័យមានសញ្ញាណយល់ដឹងពីសីលធម៌ដ៏បរិសុទ្ធរបស់ព្រះពុទ្ធជាម្ចាស់។

នៅក្នុងសាលារៀន គេអាចបញ្ចូលគោលគំនិតសំខាន់ៗក្នុងសាលាស្តីពី បាវចនាជាតិ សាសនា និងព្រះមហាក្សត្រដែលបណ្តុះស្មារតីឱ្យសិស្សមានស្មារតីស្រឡាញ់ជាតិ។ ការបញ្ចូលគំនិតទស្សនៈក្នុងការអប់រំតាមសាលាមានគុណប្រយោជន៍ ពង្រឹងបន្ថែមនូវវិន័យសិក្សា ឥរិយាបថល្អប្រពៃ និងចរិយាធម៌។ ជាពិសេសធ្វើឱ្យសិស្សយល់ដឹងដោយខ្លួនឯង មានសីលធម៌ មនសិការខ្លួនឯង និងពោរពេញដោយស្មារតីទទួលខុសត្រូវ។ ជាការកត់សម្គាល់ នៅក្នុងកម្មវិធីសិក្សាធ្វើឱ្យសិស្សប្រតិបត្តិបានល្អប្រពៃនៅក្នុងគន្លងជីវិតមានអត្តចរិតចាស់ទុំ មានការចេះក្រែងរអែងជនដទៃ។ កម្មវិធីព្រះពុទ្ធសាសនាក្នុងសាលារៀនបណ្តុះសីល សមាធិ និងបញ្ញាដែលជួយតម្រែតម្រង់សេចក្តីល្អ មានការផ្ចង់គំនិត និងមានភាពវៃឆ្លាតក្នុងការរស់នៅ។ ជាពិសេសធ្វើឱ្យសិស្សនិស្សិតមានបញ្ញាឈ្លាសវៃ និងមានឆន្ទៈតស៊ូនៅក្នុងជីវិត។ មិនត្រឹមតែប៉ុណ្ណោះព្រះធម្មទេសនាបានជួយឱ្យសិស្ស និស្សិតមានភាពភ្លឺស្វាងក្នុងផ្លូវគំនិត ចេះអប់រំផ្លូវចិត្តខ្លួនឯងចេះត្រងត្រាប់យកនូវសេចក្តីល្អ និងប្រឹងប្រែងកសាងខ្លួនឱ្យក្លាយជាមនុស្សល្អនៅក្នុងសង្គម។ ជាសិស្សគប្បីមានការប្រឹងប្រែងរៀនសូត្រ មានស្មារតីខ្ជាប់ខ្ជួនគ្រប់កាលៈទេសៈនៅក្នុងជីវិតសិក្សារបស់ខ្លួន។

ព្រះសង្ឃជាតួអង្គយ៉ាងសំខាន់ជួយផ្តល់ឱវាទដល់សិស្ស លោកគ្រូអ្នកគ្រូ និងអាណាព្យាបាលសិស្សបានល្អប្រពៃ។

## គ.២-ការអប់រំសីលធម៌នៅតាមអង្គភាព ស្ថាប័ន និងតាមមណ្ឌលកែប្រែ

នៅតាមអង្គភាព មន្ទីរស្ថាប័ន ពន្ធនាគារជាដើម យើងក៏ធ្លាប់ឃើញព្រះសង្ឃអប់រំសីលធម៌ដល់អ្នកទាំងអស់ឱ្យចេះមេត្តាគ្នា សន្តោសដល់គ្នា ប្រកបដោយគុណធម៌។ នៅក្នុងស្ថាប័នមិនថារដ្ឋ ឬឯកជនប្រសិនបើមេដឹកនាំនិងកូនចៅក្រោមឱវាទយល់គ្នា ចេះសន្តោសដល់គ្នាប្រៀបបានឪពុកនិងកូន ឬមេគ្រួសារ និងកូនចៅក្រោមបង្គាប់ ទោះមានបញ្ហាអ្វីក៏ដោយ យើងអាចប្រើយន្តការសម្របសម្រួល និងស្រាយបញ្ហាដោយធម៌អហិង្សា។

ការរស់នៅជាមួយនឹងគ្នាប្រកបដោយភាពសុខដុមគឺអាស្រ័យធម៌មេត្តាដែលព្រះសង្ឃបានទូន្មាន ស្របដូចគុណកថាមួយចែងថា «ពិសាផ្លែប្រាំ ពិសារសធម៌ ពិសាសត្យា ពិសាសីលទាន ទ្រើសទ្រង់ករុណា ពិសារសេវា ចាចេញមធូរ[8]»។ ពោលគឺការប្រកាន់យកការអប់រំតាមបែបព្រះពុទ្ធសាសនាបានផ្ដល់នូវសេចក្ដីសុខ និងការគោរពស្រឡាញ់ពីមជ្ឈដ្ឋានជុំវិញ។ នៅតាមមណ្ឌលកែប្រែ ពន្ធនាគារវិញ ព្រះសង្ឃបានអប់រំអ្នកទោសឱ្យលះបង់អំពើបាបកំណាច ហើយព្យាយាមកសាងខ្លួនឱ្យបានល្អ នៅពេលដែលខ្លួនចាកចេញពីពន្ធនាគារទៅ។ ជាគោលការណ៍សម្រាប់មនុស្សគឺប្រកាន់ឱ្យបានសីលប្រាំដែលជាសីលដ៏ប្រពៃសម្រាប់មនុស្សទូទៅ។ ការចូលរួមចំណែករបស់ព្រះសង្ឃគឺជាគុណតម្លៃដ៏ថ្លៃថ្លាណាស់ នាំឱ្យមនុស្សវៀរចាកអំពើបាប និងលះបង់សេចក្ដីបាបទាំងឡាយទាំងពួង ហើយស្រវាចាប់យកតែសេចក្ដីល្អដើម្បីខ្លួនឯង គ្រួសារ និងសង្គមជាតិ។

ព្រះធម្មទេសនាគឺជាថ្នាំទិព្វជួយអប់រំផ្លូវចិត្តឱ្យមានសីលធម៌ សុជីវធម៌ សុភាវធម៌ និងគុណធម៌ ព្រមទាំងប្រកាន់ខ្ជាប់នូវធម៌អហិង្សាដែលជាមាគ៌ាឆ្ពោះទៅរកសុខសន្តិភាព។

## គ.៣-ការអប់រំសីលធម៌បណ្ដុះនិស្ស័យ និងឱ្យមនុស្សលះបង់អំពើអបាយមុខ

ជាការពិតណាស់ ព្រះធម្មទេសនាបានជួយតម្រង់ហាត់ពត់លត់ដំតម្រង់និស្ស័យរបស់មនុស្សឱ្យមានពន្លឺបញ្ញា។ មនុស្សកាលណាស្គាល់ផ្លូវត្រូវហើយ ធ្វើឱ្យមនុស្សមានក្ដីសង្ឃឹម បណ្ដុះក្ដីសង្ឃឹម ជួយដល់មនុស្សឱ្យមានពន្លឺក្នុងជីវិត។ យ៉ាងណាមិញ នៅក្នុងសង្គមកម្ពុជាយើង ព្រះសង្ឃដើរតួនាទីសំខាន់ណាស់ ជួយបណ្ដុះបណ្ដាលអប់រំបន្ទុំនិស្ស័យដល់សត្វលោកឱ្យដើរផ្លូវត្រូវ និងលះបង់អំពើបាបទាំងឡាយ។

ក្នុងនោះការប្រព្រឹត្តនូវអបាយមុខដែលនាំជីវិតជួបតែទុក្ខសោក ឬបាត់បង់សតិស្មារតីដូចជា «លោកហៅឆ្កួតបី មួយឆ្កួតនឹងស្រី មួយឆ្កួតនឹងស្រា មួយឆ្កួតល្បែងពាលា លេងបៀប៉ោជួកំចាត់។ ទាក់មាន់ទាក់ទទា ជល់ភ្នាល់គ្នា បរបាញ់សត្វ អន្ទាក់ដាក់បង្កាត់ ល្បែងអស់នោះមិនកំណើត»[9]។ ពោលគឺជាសេចក្ដីឆ្កួតក្រៃលែងកន្លង។ នៅពេលដែលមនុស្សលុះក្នុងអបាយមុខ ចិត្តរបស់គេរមែងពេញចិត្តពេញថ្លើមជាប់ស្អិតជិតជាប់សតិអារម្មណ៍មិនងាយនឹងដកចិត្តវិញឡើយ។ ប៉ុន្តែនៅពេលដែលគេពើបប្រទះនឹងសេចក្ដីទុក្ខសោក ទើបយល់ថាអំពើទាំងនោះមិនមែនជាកុសលឡើយ។ ព្រះសាស្ដាបានជួយអប់រំមនុស្សឱ្យមាន

[8] ច្បាប់ព្រះរាជសម្ភារ

[9] ច្បាប់ប្រុស, បណ្ឌិត ម៉ឺន ម៉ៃ

សេចក្ដីសង្ឃឹម និងមានការសិក្សាយល់ដឹងជ្រៅជ្រះនៅក្នុងជីវិត។ ជាពិសេសព្រះធម្មទេសនាបានណែនាំផ្លូវឱ្យមនុស្សស្គាល់ពីផលវិបាកនៃទុក្ខដែលកើតឡើងមកពីអំពើអបាយមុខដូចជាការប្រព្រឹត្តល្បែង ស្រាស្រី ជាដើម។ យើងអាចនិយាយបានថា កាលណាមនុស្សជួបទុក្ខ ស្គាល់ពីសេចក្ដីទុក្ខ នោះនាំឱ្យជីវិតគេស្គាល់ពីប្រភពទុក្ខ ហើយលះបង់ឱ្យឆ្ងាយពីគ្រឿងអបាយនានា។ ព្រះធម្មទេសនាពិតជាអស្ចារ្យខ្លាំងណាស់។ ព្រះធម្មទេសនាបានជួយលើកកម្ពស់សីលធម៌ក្នុងសង្គមខ្មែរយើងបច្ចុប្បន្ននេះឱ្យមានសណ្ដាប់ធ្នាប់ និងលើកតម្កើងតម្លៃមនុស្សឱ្យខ្ពស់ជាងសត្វ។ នៅសម័យឌីជីថលនេះ ព្រះធម្មទេសនានៅតាមបណ្ដាញសង្គមក៏បានជួយពញ្ញាក់ស្មារតីយុវជនឱ្យស្គាល់ពីតម្លៃនៃការសិក្សា ចៀសឱ្យឆ្ងាយពីគ្រឿងញៀន កុំយកស្នេហាមកប្រឡែងលេងក្នុងវ័យសិក្សា និងចេះលើកស្ទួយតម្លៃនៃវប្បធម៌ជាតិជាគោល។

សរុបមក ព្រះពុទ្ធសាសនាមានតួនាទីអប់រំមនុស្ស ប្រដៅមនុស្សឱ្យរស់នៅក្នុងសេចក្ដីសុខស្ងប់គ្រប់ប្រការពីបច្ចុប្បន្នរហូតដល់បរលោកនាយ។

### ឃ- ការអប់រំសីលធម៌ក្នុងពិភពលោក

ក្នុងគោលដៅអប់រំពិភពលោកទាំងមូលឱ្យមានសន្តិភាព ស្ថិតក្រោមម្លប់សន្តិភាព។ មាគ៌ារបស់ព្រះពុទ្ធអប់រំមនុស្សដោយធម៌អហិង្សា ប្រកាន់ខ្ជាប់នូវសេចក្ដីសុខ មិនមានការរើសអើងគ្នា ហើយចេះរួមរស់ជាមួយគ្នាក្រោមដំបូលផ្ទៃមេឃតែមួយ។

តាមបទពិសោធន៍ប្រទេសកម្ពុជា ធម្មយាត្រារបស់ព្រះមហាឃោសានន្ទបានដឹកនាំធម្មយាត្រាដើម្បីបញ្ចប់ជម្លោះនៅប្រទេសកម្ពុជា។ វិវាទបានកើតឡើងចាប់តាំងពីមានសង្គ្រាមស៊ីវិលនៅកម្ពុជា ពោលគឺនៅពេលដែលសេនាប្រមុខ លន់ នល់ បានធ្វើរដ្ឋប្រហារទម្លាក់សម្ដេចព្រះនរោត្តមសីហនុដែលគ្រានោះប្រទេសកម្ពុជាធ្លាក់ចូលទៅក្នុងភ្នក់ភ្លើងសង្គ្រាមអូសបន្លាយអស់រយៈកាលជាងពីរទសវត្ស។ វត្តមានព្រះពុទ្ធសាសនាបានរួមចំណែកក្នុងការស្វែងរកសន្តិភាពនៅប្រទេសកម្ពុជា។ យើងបានឃើញថានៅពេលមានការជួបចរចាស្វែងរកសន្តិភាពរមែងមានវត្តមានរបស់ព្រះសង្ឃរាជទាំងពីរគណៈគឺ គណៈមហានិកាយ និងគណៈធម្មយុត្តិកនិកាយបានចូលរួមជយន្តោប្រោះព្រំឱ្យពរជ័យដល់ចតុភាគីឱ្យមានការជួបចរចាគ្នាប្រកបដោយសន្តិវិធីក្នុងការរិះរកដំណោះស្រាយបញ្ចប់សង្គ្រាមនៅប្រទេសកម្ពុជា។ រីឯព្រះធម្មយាត្រាបានជួយអប់រំបន្ទំនិស្ស័យជួយផ្សះផ្សាផ្លូវចិត្តតាមបែបព្រះពុទ្ធសាសនាឱ្យខ្មែរបញ្ឈប់នូវការបង្ហូរឈាមនឹងគ្នាឯងបន្តទៀតទៅ។ ពោលគឺទៅដល់ទីណា ព្រះសង្ឃរមែងទេសនាដល់ពុទ្ធបរិស័ទឱ្យមានសេចក្ដីសង្ឃឹម។

ព្រះពុទ្ធសាសនាជួយបណ្តុះបញ្ញាញាណដល់មនុស្សជាតិឱ្យបានរីកលូតលាស់សមជាសង្គមពុទ្ធិ។ ព្រះពុទ្ធសាសនាបានជួយលុបបំបាត់នូវការរើសអើងវណ្ណៈ ពូជសាសន៍នៅក្នុងសង្គម។ បើនិយាយពីសង្គមខ្មែរផង ទស្សនៈរបស់លោកឡឺក្លែរដែលជឿថា "ព្រះពុទ្ធសាសនាជាកត្តាដែលធ្វើឱ្យមានការលុបបំបាត់នូវប្រព័ន្ធវណ្ណៈ[10]»។ នៅក្នុងសាកលលោកសព្វថ្ងៃនេះមានសង្គ្រាមជម្លោះប្រដាប់អាវុធកើតឡើង។ ជម្លោះនេះថ្វីត្បិតតែបណ្តាលមកពីភូមិសាស្ត្រនយោបាយ និងកត្តាសេដ្ឋកិច្ច ឬកត្តាសន្តិសុខពិភពលោក ប៉ុន្តែក៏ជះឥទ្ធិពលដល់សាសនាដែរ។ សាសនាមានតួនាទីចាំបាច់ដើម្បីបញ្ចប់ជម្លោះនេះដោយសន្តិវិធី។ ពោលគឺកាលណាមានសង្គ្រាមកើតឡើងបណ្តាលឱ្យមនុស្សរងទុក្ខវេទនា ស្លាប់ របួសជាច្រើន និងបន្សល់ទុកសោកនាដកម្មឈឺចាប់ខ្លោចផ្សាពិបាកហួសនឹងថ្លែង។ ត្រង់ន័យនេះ ព្រះពុទ្ធសាសនាមានតួនាទីផ្សាយធម៌មេត្តាដល់មនុស្សឱ្យចេះស្រឡាញ់គ្នា បញ្ឈប់ជម្លោះដោយសន្តិវិធីដោយប្រកាន់ខ្ជាប់នូវធម៌អហិង្សា។

សរុបមក ព្រះពុទ្ធសាសនាមានតួនាទីផ្តល់សេចក្តីសុខ សន្តិភាពដល់មនុស្សជាតិដោយមិនមានការរើសអើង ឬប្រកាន់បក្សពួកអ្វីឡើយ។

## ខ- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌ក្នុងសង្គមខ្មែរ

### ខ.១- តួនាទីវត្តអារាមក្នុងការលើកកម្ពស់ការអប់រំសីលធម៌ក្នុងសង្គមខ្មែរ

វត្តអារាមជាទីពឹងពាក់របស់ប្រជារាស្ត្រខ្មែរតាំងពីសម័យបុរាណកាលរហូតមកដល់បច្ចុប្បន្នយើងនេះឯង។ នៅពេលមានតម្រូវការណាមួយ គេតែងតែពឹងពាក់អាស្រ័យដល់វត្តអារាមមិនដែលខាន។ វត្តអារាមដើរតួនាទីយ៉ាងសំខាន់នៅក្នុងការចូលរួមតម្រែតម្រង់ស្មារតីមនុស្សឱ្យចេះធ្វើបុណ្យទាន ចេះសន្សំបុណ្យកុសល និងធ្វើសេចក្តីល្អ។ មនុស្សគ្រប់គ្នានៅពេលណាដែលជួបនឹងសេចក្តីភ័យខ្លាច ក៏ងាកមករកព្រះធម៌ ហើយមានព្រះសង្ឃជួយអប់រំទូន្មានចិត្តឱ្យស្ថិតក្នុងផ្លូវគុណធម៌។

---

[10] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សទី១នៃគ្រិស្តសករាជរហូតមក, និពន្ធដោយលោកអាដេម៉ារ ឡឺក្លែរ អតីតរ៉េស៊ីដង់បារាំងប្រចាំប្រទេសកម្ពុជា, ប្រែសម្រួលដោយ ទេព ម៉េងឃាន ហៅ ទីឃាយុ, មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ពលើកទីមួយ ឆ្នាំ២០០៥

## ខ.២-តួនាទីព្រះសង្ឃក្នុងការលើកកម្ពស់ការអប់រំសីលធម៌ក្នុងសង្គមខ្មែរ

ព្រះសង្ឃជាស្រែបុណ្យរបស់ប្រជាពុទ្ធបរិស័ទ។ កាលណាព្រះសង្ឃនិមន្តបិណ្ឌបាត្រ ព្រះសង្ឃរមែងអប់រំទូន្មានប្រៀនប្រដៅដល់មនុស្សម្នាទាំងឡាយដោយមិនមានសេចក្ដីរើសអើង។ ជាក់ស្ដែងយើងបានឃើញថា នៅពេលមានបញ្ហាណាមួយកើតឡើង ព្រះសង្ឃបានជួយចូលរួមផ្សះផ្សាផ្លូវចិត្តមនុស្សឱ្យបានជ្រះស្រឡះថែមទៀតផង។

ព្រះសង្ឃបានជួយពន្លត់ភ្លើងកំហឹងរបស់មនុស្សឱ្យចេះសង្កត់ចិត្ត ហើយឱ្យមានអារម្មណ៍កក់ក្ដៅ។ ជាក់ស្ដែងណាស់នៅក្នុងសង្គមខ្មែរ នៅពេលមាននរណាម្នាក់មានបញ្ហាគ្រួសារ ហើយបានពិគ្រោះយោបល់ជាមួយនឹងព្រះសង្ឃធ្វើឱ្យចិត្តគេត្រជាក់ ចេះសង្កត់ចិត្ត សុខចិត្តចុះចាញ់ដោយមិនមានការទាមទារអ្វីទាំងអស់។ មិនចង់ឈ្នះដៃគូរបស់ខ្លួន យកធម៌អហិង្សាជាគោល និងមានការពិចារណាជាគោលផងដោយពិចារណាថា កាលណាយើងខឹង នាំឱ្យខុស នាំឱ្យខាត បាត់បង់ប្រយោជន៍និងបាត់កិត្តិយស ព្រមទាំងសេចក្ដីថ្លៃថ្នូរ។ ព្រះសង្ឃមិនត្រឹមតែអប់រំយើងឱ្យដើរផ្លូវល្អប៉ុណ្ណោះទេ ថែមទាំងជួយពន្លត់កំហឹងឱ្យរលត់។ ព្រះសម្មាសម្ពុទ្ធរមែងពោលថា«ចូរកុំទ្រទ្រង់ភ្លើងចំណង់ដោយអំពើអាក្រក់ឡើយ»។ នៅពេលមានពិធីបុណ្យទាននានាដូចជាបុណ្យចម្រើនព្រះជន្ម ព្រះសង្ឃបានអប់រំឱ្យដឹងគុណម៉ែឪ ឱ្យចេះតបស្នងសងគុណគាត់ ឱ្យចេះធ្វើបុណ្យទាន់ខែក្ដី។ នៅក្នុងពិធីមង្គលការខ្លះវិញ ព្រះសង្ឃ ឬអាចារ្យក៏បានលើកយកព្រះធម្មទេសនាមកអប់រំទូន្មានគូស្រករថ្មោងថ្មីឱ្យប្រកាន់ខ្ជាប់នូវធម៌សង្គ្រោះដល់គ្នាទៅវិញទៅមក។

សរុបមក ព្រះសង្ឃមានតួនាទីអប់រំសីលធម៌យ៉ាងជ្រាលជ្រៅដល់មនុស្សម្នានៅក្នុងសង្គមមិនថា ជាពលរដ្ឋ សិស្សសាលា ប្ដីប្រពន្ធ ឬមេដឹកនាំនោះទេ ព្រះសង្ឃបានចែករំលែកនូវធម្មទានដ៏ប្រសើរ។

## ខ.៣-តួនាទីអាចារ្យ និងយាយជី តាជីក្នុងការអប់រំសីលធម៌សង្គមខ្មែរ

តាមរយៈព្រះពុទ្ធសាសនាបានជួយអប់រំមនុស្សម្នាតាមរយៈអាចារ្យ យាយជី តាជី ដែលបានរស់នៅបម្រើដល់ព្រះពុទ្ធសាសនា។ ដូចអ្វីដែលយើងបាននិយាយមកហើយថា អាចារ្យមានតួនាទីសំខាន់ណាស់នៅក្នុងសង្គមខ្មែរ។ សម័យកាលណាក៏ដោយ ប្រសិនបើគ្មានអាចារ្យនោះកម្មវិធីមួយមិនអាចប្រព្រឹត្តទៅបានរលូនឡើយ។

អាចារ្យជាអ្នករៀបចំកិច្ចពិធីនានាមុនពេលដែលត្រូវនិមន្តព្រះសង្ឃមកចម្រើនកិច្ចពិធីបែបសាសនា ឬប្រោះព្រំជាដើម។ គ្រប់ពិធីទាំងអស់រមែងមានលោកអាចារ្យ យាយជី តាជីចូលរួម។ ពោលគឺទាំងនៅក្នុង ពិធីមង្គលការ ពិធីបុណ្យទាននានា និងកិច្ចពិធីណាក៏ដោយ អាចារ្យជាចលករមួយដ៏មានសារៈសំខាន់ដែល អាចប្រាប់ពីសេចក្តីត្រូវការ និងដឹងកិច្ចដែលជាទំនៀមទម្លាប់នៃកម្មវិធីនានា។ អាស្រ័យហេតុនេះអាចារ្យ គប្បីមានចំណេះពុទ្ធិផ្នែកអាណាចក្រ និងពុទ្ធចក្រឱ្យបានជ្រាលជ្រៅ។ ពីព្រោះអាចារ្យភាគច្រើនសុទ្ធតែ ធ្លាប់បានបួសរៀនជាព្រះសង្ឃ ទើបអាចចេះធម៌អាថ៌ ហើយយល់ដឹងពីបែបបទព្រះពុទ្ធសាសនា។ នៅ ពេលមានពិធីបុណ្យទាននានា អាចារ្យរមែងឱ្យពរដល់ប្រជាពុទ្ធបរិស័ទឱ្យបានសេចក្តីសុខចម្រើនមានលាភ មានជ័យ និងអប់រំដោយជាឱវាទល្អៗដែលយើងអាចគ្រងគ្រាប់រក្សាទុកក្នុងជីវិតថែមទៀតផង។ នៅក្នុង អាវាហមង្គល អាចារ្យប្រដៅទូន្មានដល់គូស្រករថ្មោងថ្មីឱ្យមានចិត្តអធ្យាស្រ័យដល់គ្នាទៅវិញទៅមក។

សរុបមក អាចារ្យជាបុគ្គលម្នាក់ដែលជួយឱ្យមនុស្សដើរទៅរកផ្លូវល្អផងដែរ ព្រោះអាចារ្យមាន ចំណេះច្រើនខាងធម៌អាថ៌បាលី ហើយចេះចាំនូវឃ្លាំងពុទ្ធវចនៈដ៏ល្អឆើតទុកគ្រាន់ទូន្មានដល់ជនានុជន។

## ខ.៤- តួនាទីឃ្លាំងវចនៈ និងការបម្រើពុទ្ធបរិស័ទ

ព្រះពុទ្ធសាសនាជាសាសនាដ៏ឧត្តមដែលបានបម្រើពុទ្ធបរិស័ទទៅតាមផ្លូវគុណធម៌។ យើងជឿថា ប្រសិនបើមិនមានគុណតម្លៃអ្វីដល់បរិស័ទដែលគោរពជឿជាក់នោះទេ ម្ល៉េះសមព្រះពុទ្ធសាសនាមិនអាច មានអត្ថិភាពនៅក្នុងសង្គមខ្មែរបានឡើយ។

ព្រះពុទ្ធសាសនាបានបម្រើប្រជាពុទ្ធបរិស័ទឱ្យស្ថិតស្ថេរជាអមតៈ និងរស់នៅយូរអង្វែងក្នុងសង្គម ខ្មែរ។ ព្រះពុទ្ធសាសនាបានជួយសង្គមយើងឱ្យមានការរីកចម្រើនតាមផ្លូវវិទ្យាសាស្ត្រផង និងតាមផ្លូវសង្គម ផង។ តួយ៉ាងតាមរយៈគោលការណ៍ព្រះពុទ្ធសាសនាដែលមានចែងនៅក្នុងនោះគឺ «ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ» ដែលជាសេចក្តីដឹងគុណចំពោះព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាទី ពឹងទីរឮក។ នៅត្រង់នេះ យើងបានដឹងថា ព្រះពុទ្ធសាសនាបានជួយដាស់តឿនឱ្យប្រជាពុទ្ធបរិស័ទមាន ជំនឿជឿជាក់លើខ្លួនឯង មានកតញ្ញូកតវេទី ចេះដឹងគុណនិងតបគុណ។ ព្រលឹងដួងជាតិបានជួយថែរក្សា ការពារស្រុកទេសយើងឱ្យបានគង់វង្សព្រោះអ្នកដឹកនាំមានធម៌កតញ្ញូ មានការចេះដឹងគុណនិងមានការ ពិចារណាខ្ពស់ដោយប្រកាន់ខ្ជាប់តាមពុទ្ធោវាទមានមេត្តា ករុណា មុទិតា និងឧបេក្ខា។

ព្រះពុទ្ធសាសនាបានបម្រើសង្គមខ្មែរ ជួយអប់រំដល់មនុស្ស តម្រែតម្រង់ផ្លូវចិត្តបរិស័ទឱ្យស្ថិតនៅក្នុងសីល សមាធិ និងបញ្ញាដែលជាមគ្គុទ្ទេសក៍នៃជីវិត។

### ១.៥.-តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅក្នុងផ្លូវជីវិតនៃមនុស្សខ្មែរ

ស្នាដៃពុទ្ធនិយម អ្នកនិពន្ធខ្មែរបានយកការប្រៀនប្រដៅផ្សេងៗរបស់បុព្វបុរសខ្មែរផ្សារភ្ជាប់ជាមួយនឹងជីវិតព្រះពោធិសត្វមកតាក់តែងកែច្នៃបញ្ចេញបញ្ចូលគំនិតទស្សនៈរបស់ខ្លួនឱ្យស្របទៅនឹងផ្នត់គំនិតប្រពៃណីទំនៀមទម្លាប់របស់ប្រជាជនខ្មែរដើម្បីបណ្ដុះស្មារតីឱ្យមនុស្សយល់ដឹងពីតម្លៃនៃជីវិត។ ក្នុងនោះអក្សរសិល្ប៍ពុទ្ធនិយមបានបណ្ដុះឱ្យខ្មែរមានការស្វែងយល់ស៊ីជម្រៅគឺតម្លៃនៃការអប់រំតាមគន្លងមាគ៌ាព្រះពុទ្ធអង្គ និងការគោរពចំពោះព្រះពុទ្ធសាសនាដូចជា៖

#### ១.៥.១- ការបណ្ដុះស្មារតីកតញ្ញូកតវេទី ព្រមទាំងការជឿជាក់លើខ្លួនឯង

អក្សរសិល្ប៍ពុទ្ធនិយមប្រៀបបានជាឱសថដ៏ស័ក្ដិសិទ្ធិគឺបានអប់រំមនុស្សខ្មែរឱ្យជឿទៅលើបុណ្យបាប ខ្លាចរអាអំពើបាប និងចៀសឱ្យឆ្ងាយពីបាបកម្មគ្រប់បែបយ៉ាង។ ស្នាដៃបានបណ្ដុះចិត្តមនុស្សខ្មែរឱ្យចេះដឹងគុណចំពោះមនុស្សដែលបានជួយសង្គ្រោះខ្លួននៅពេលដែលខ្លួនជួបទុក្ខលំបាក។ នៅក្នុងសង្គមយើងនេះ យើងបានសង្កេតឃើញថា មនុស្សមានច្រើនប្រភេទណាស់ មានល្អ មានអាក្រក់ និងមានចិត្តជាគុណធម៌ជាដើម។ នៅក្នុងសង្គមទៀតសោត រមែងមានរឿងរ៉ាវជាច្រើនដែលយើងមិននឹកស្មានដល់។ ដូចនេះគឺមានតែការខិតខំប្រព្រឹត្ត សាងតែអំពើល្អគ្រប់បែបយ៉ាង ទើបនាំឱ្យមនុស្សមានសុភមង្គល និងមានចិត្តស្ងប់នៅពេលដែលបានជួយសង្គ្រោះជនណាម្នាក់។ ខ្មែរយើងតែងមានជំនឿថា ការជួយសង្គ្រោះមនុស្សសូម្បីតែម្នាក់នៅពេលដែលគេត្រូវការជំនួយ ល្អជាងការធ្វើបុណ្យ៧វត្ត។ ជាមួយគ្នានេះ ស្នាដៃពុទ្ធនិយមបានបណ្ដុះទស្សនៈឱ្យមនុស្សជឿជាក់លើកម្លាំងផ្ទាល់ខ្លួន មិនមានទស្សនៈផ្ដេកផ្ដួលដោយសេចក្ដីខ្ជិលច្រអូសសោះឡើយ។

#### ១.៥.២- ការអប់រំបណ្ដុះស្មារតីឱ្យមនុស្សជឿលើអំពើបុណ្យបាប

តាមរយៈស្នាដៃមួយចំនួនដូចជា ពុទ្ធិសែននាងកង្រី មរណមាតា សព្វសិទ្ធិ កវីនិពន្ធខ្មែរបានលើកឡើងពីការបញ្ជាកម្មផល។ តួអង្គដែលសាងអំពើអាក្រក់ រមែងមានកម្មពៀរវេរា ហើយត្រូវទទួលរងបាបកម្មចំពោះអំពើដែលខ្លួនបានសាងយ៉ាងសែនទារុណ។ នៅក្នុងរឿងពុទ្ធិសែននាងកង្រីបានបង្ហាញថា ពុទ្ធិសែន

និងនាងកម្រើព្រាត់ប្រាសគ្នាដោយសារតែកម្មផល។ ចំណែកនាងទាំង១២ ត្រូវគេខ្វេះភ្នែក ខ្វាក់ភ្នែកដូច្នេះ ដោយសារតែកាលពីជាតិមុន នាងទាំងដប់ពីរនាំគ្នាខ្វេះភ្នែកត្រី ទើបជាតិបច្ចុប្បន្នត្រូវគេខ្វេះភ្នែកវិញ ហើយរស់នៅអន្ទោលអន្ទោកវេទនាពន់ពេកក្រៃ។ នៅក្នុងរឿងមរណមាតា តួអង្គដែលប្រព្រឹត្តនូវអំពើបាបកម្មគឺនាងមេម៉ាយនាមកាឡី និងកូនៗ ទីបំផុតត្រូវកម្មពៀរវារមកផ្តន្ទាយ៉ាងទាន់ហន់ជាទីបំផុត។ អំពើអាក្រក់នេះគឺជាអ្វីដែលកវីនិពន្ធអប់រំមនុស្សឱ្យខ្លាចបាប កុំប្រព្រឹត្តនូវអំពើបាបកម្មឱ្យសោះ។

ស្នាដៃពុទ្ធនិយមបានអប់រំ ដាស់តឿនក្រើនរំឭកមនុស្សខ្មែរឱ្យជឿលើកម្មផល វៀរចាកបាបកម្មគ្រប់យ៉ាង ងាកមកប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវសីល ចម្រើន ភាវនាជាប្រចាំ។

### ខ.៥.៣- ការបណ្តុះឱ្យមានស្មារតីតស៊ូគ្រប់កាលៈទេសៈ

ជាការពិតណាស់នៅក្នុងស្នាដៃអក្សរសិល្ប៍ពុទ្ធនិយមមានតួនាទីយ៉ាងសំខាន់មួយទៀត គឺការអប់រំបានសេចក្តីថាជាការទូន្មានប្រៀនប្រដៅដល់មនុស្សខ្មែរឱ្យមានចិត្តតស៊ូគ្រប់កាលៈទេសៈ និងយកទស្សនៈទ្រឹស្តីព្រះពុទ្ធសាសនាមកជាគ្រឿងអប់រំផ្លូវចិត្តរបស់ខ្លួន។ យើងអាចលើកឧទាហរណ៍ជាក់ស្តែងគឺបណ្ឌិត ជ័យ នន្ទ ដែលជាកវីឆ្នើមនៅសម័យឧដុង្គ ពោលគឺនៅពេលដែលលោកជួបនូវទុក្ខក្រៀមក្រំពីព្រោះតែការបែកបាក់ព្រាត់ប្រាសពីប្រពន្ធកូន លោកបានយកធម៌ព្រះពុទ្ធមកអប់រំ និងញ៉ាំងចិត្តឱ្យបានជ្រះថ្លា។ បណ្ឌិត ជ័យ នន្ទ ជាកវីឆ្នើមនាសម័យកាលនោះដែលបានពលិកម្មដើម្បីជាតិ សាសនា និងព្រះមហាក្សត្រ។ ជាពិសេសនៅពេលជួបទុក្ខលំបាក ឱ្យមនុស្សនឹករឭកដល់គុណព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មាតាបិតា និងគ្រូអាចារ្យរបស់ខ្លួន ហើយពុះពារបន្តដំណើរជីវិតទៅមុខទៀតដោយជម្នះឱ្យបានគ្រប់កាលៈទេសៈ។

### ខ.៥.៤- ការអប់រំសីលធម៌ និងការព្យាបាលជំងឺផ្លូវចិត្ត

អក្សរសិល្ប៍ពុទ្ធនិយមប្រៀបបានដូចជាឱសថដ៏ស័ក្តិសិទ្ធិដែលបានជួយព្យាបាលជំងឺផ្លូវចិត្តប្រជាជនខ្មែរឱ្យមានសេចក្តីសុខស្ងប់ស្ងាត់។ អក្សរសិល្ប៍ពុទ្ធនិយមជាស្នាដៃដ៏មានតម្លៃជាទីបំផុតដែលអាចជួយជម្រុះចោលនូវរឿងសៅហ្មងទាំងឡាយបាន។

នៅពេលដែលប្រជាជនខ្មែរសម្រាកពីការងារស្រែចម្ការ គឺពួកគាត់តែងតែនិទានរឿងដែលបានចងចាំ ឬការនិយមសូត្រកំណាព្យឱ្យស្តាប់ក៏ជាវិធីមួយល្អផងដែរ។ ត្រង់នេះហើយ ទើបយើងអាចនិយាយបានថា ស្នាដៃពុទ្ធនិយមជាឱសថព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនឱ្យល្វែល្វើយពីការលំបាក។ នៅសម័យក្រោយអង្គរ យើងបានដឹងថា ប្រទេសជាតិកំពុងញាំញីដោយវិបត្តិជាច្រើនដែលកើតឡើងដោយសារជម្លោះ

ផ្ទៃក្នុង និងបច្ចាមិត្តពីខាងក្រៅ។ ក្នុងនោះសត្រូវខ្លាំងគឺសៀម ហើយនឹងយួនតែងតែចិញ្ចឹមចិត្តមកលើនគរខ្មែរ ហើយធ្វើសង្គ្រាមនៅលើទឹកដីខ្មែរដោយបែងចែកម្ខាងម្នាក់នៃទន្លេ មេគង្គជាខ្សែបន្ទាត់កាន់កាប់រៀងខ្លួន។ ម្ល៉ោះហើយ អក្សរសិល្ប៍ពុទ្ធនិយមបានជួយបន្ធូរបន្ថយភាពតានតឹងផ្នែកផ្លូវចិត្តរបស់គេ ដោយប្រជារាស្ត្រខ្មែរងាកមកមានជំនឿទៅលើព្រះរតនត្រ័យ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ថាអាចជួយស្រោចស្រង់ពួកគេឱ្យមានសេចក្តីសង្ឃឹម។ នេះជាព្រលឹងដួងកែវធំណាស់សម្រាប់ជាតិ គឺព្រលឹងសាសនាដែលបានជួយជំរុញទឹកចិត្តប្រជារាស្ត្រខ្មែរឱ្យមានសេចក្តីសង្ឃឹមនៅក្នុងជីវិត។ ដូចដែលយើងបានដឹងស្រាប់មកហើយថាកាលពីសម័យដើមវត្តអារាមជាទីកន្លែងបណ្តុះបណ្តាលការសិក្សារៀនសូត្រសព្វគ្រប់សារពើ។ កូនប្រុសច្រើនតែមានឱកាសក្នុងការរៀនសូត្របួសរៀននូវវិជ្ជាផ្នែកខាងព្រះពុទ្ធសាសនា និងកិច្ចការងារ ហត្ថកម្មសិល្បៈជាដើម។

ស្នាដៃពុទ្ធនិយមបានជួយព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនខ្មែរនៅគ្រប់សម័យកាលឱ្យបានស្រាកស្រាន្ត បន្ធូរបន្ថយភាពតានតឹងក្នុងផ្លូវអារម្មណ៍ និងមានស្មារតីតស៊ូនៅក្នុងជីវិត។

### ខ.៥.៦- ការអប់រំក្រមវិជ្ជាជីវៈ និងសីលធម៌វិទ្យាសាស្ត្រ

នៅក្នុងស្នាដៃពុទ្ធនិយមបានបណ្តុះនូវគំនិតវិទ្យាសាស្ត្រដល់សង្គមខ្មែរនៅសម័យកាលនោះមកម្ល៉េះ ពោលគឺជាស្មារតីវិទ្យាសាស្ត្រដែលកើតឡើងតាមរយៈការស្រមើស្រមៃរបស់កវីនិពន្ធ ប៉ុន្តែបានឆ្លាក់ជាប់នូវការចេះដឹងលើការច្នៃប្រឌិតមធ្យោបាយធ្វើដំណើរដល់មនុស្សខ្មែរក៏ដូជាពិភពលោកទាំងមូល។

តាមរយៈស្នាដៃរឿង ហង្ស យន្ត បានផ្តល់ចំណេះដឹងវិទ្យាសាស្ត្រដល់មនុស្សខ្មែរឱ្យមានគំនិតច្នៃប្រឌិតខ្ពស់។ ដោយកវីនិពន្ធប៉ិនប្រសប់ក្នុងការរកនឹកត្រិះរិះបង្កើតយានជំនិះដែលកាលនោះ ពិភពលោកទាំងមូលពុំទាន់មានការរីកចម្រើនផ្នែកវិទ្យាសាស្ត្រជឿនលឿននៅឡើយផង។ ពោលគឺអ្នកនិពន្ធបានរកនឹកយានជំនិះដែលអាចបញ្ជាតាមខ្សែញាក់ មានស្លាបដោយគ្រឿងយន្ត។ ម្យ៉ាងវិញទៀត របស់នេះក៏អាចត្រូវភ្លើងឆេះនាំឱ្យគ្រោះថ្នាក់ផងដែរ។ ស្នាដៃរឿង ហង្ស យន្ត ពិតជាវិសេសវិសាលខ្លាំងណាស់។ ព្រោះបានផ្តល់ចំណេះដឹងដល់មនុស្សខ្មែរឱ្យមានគំនិតច្នៃប្រឌិតសម្រាប់ការរស់នៅជាប្រចាំ និងហ៊ានជម្នះគ្រប់ឧបសគ្គមិនរាថយ។

## ១.៥.៧- ការអប់រំឱ្យមានសន្តិភាពផ្លូវចិត្ត (សីល សមាធិ បញ្ញា)

ស្នាដៃពុទ្ធនិយមប្រៀបបានជាឱសថដ៏ល្អឆើតសម្រាប់ព្យាបាលជំងឺផ្លូវចិត្តរបស់ប្រជាជនខ្មែរនៅសម័យកាលនោះ។ ស្នាដៃនោះទៀតសោតបានបណ្តុះស្មារតីអហិង្សា ការបញ្ចប់ ទំនាស់ដោយសន្តិវិធីដោយយកគន្លង ឬមាគ៌ាកណ្តាលនៃព្រះពុទ្ធបរមគ្រូជាគោល។

ស្នាដៃពុទ្ធនិយមតែងរំឭកដល់ត្រៃសរណគមន៍ថា «ពុទ្ធំ សរណំ គច្ឆាមិ ធម្មំ សរណំ គច្ឆាមិ សង្ឃំ សរណំ គច្ឆាមិ » ដែលបានន័យជាសម្រាយថា«ព្រះពុទ្ធ ជាទីពឹង ព្រះធម៌ជាទីពឹង ព្រះសង្ឃជាទីពឹង» ហើយប្រជាជនខ្មែរតែងចងចាំទុក។ ពោលគឺនៅពេលដែលខ្មែរជួបគ្រោះភ័យ សេចក្តីសោកទាំងឡាយប្រជារាស្ត្រខ្មែរតែងនឹកដល់គុណកែវទាំងបីជាទីពឹងជាទីរំឭកដែលនាំឱ្យចិត្តជ្រះថ្លា ស្ងប់ស្ងាត់ផ្លូវអារម្មណ៍ និងពោរពេញដោយថាមពលផ្លូវចិត្តមានស្មារតីតស៊ូមិនរាថយឡើយ។ ស្នាដៃពុទ្ធនិយមតែងរំឭកដល់គុណកែវទាំងបី គុណមាតាបិតា គុណគ្រូបាអាចារ្យ និងគុណរៀមច្បងដែលសបញ្ជាក់ថា ខ្មែរជាជាតិសាសន៍មួយនិយមការដឹងគុណកតញ្ញូកតវេទី និងមានស្មារតីអហិង្សា ប្រកាន់ខ្ជាប់តែអំពើសុចរិតទៀងត្រង់មិនឱ្យប្រាសចាកពីគន្លងឱវាទព្រះពុទ្ធសមណគោត្តមឡើយ។ អក្សរសិល្ប៍ពុទ្ធនិយមសាបព្រោះតែសេចក្តីល្អ ធម៌អហិង្សា និងស្វែងរកតែសេចក្តីសុខសន្តិភាពដល់មនុស្សជាតិគ្រប់កាលៈទេសៈ ដោយមិនចង់ឃើញការបង្ហូរឈាមរវាងជាតិសាសន៍ណាមួយនោះទេ។ នៅក្នុងស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមក៏បានបង្ហាញពីរាជទសពិធរាជធម៌ ជាពិសេសក្នុងរឿងវិធុរបណ្ឌិត ដំណើររឿងផ្នែកខ្លះបានបង្កប់នូវទសពិធរាជធម៌ ឬច្បាប់សម្រាប់អប់រំមនុស្សក្នុងរាជត្រកូលដូចជាច្បាប់ ឬវិន័យសម្រាប់អប់រំបុគ្គលជាអ្នករាជការនៅក្នុងប្រទេសទាំងមូលដែរ។ ខ្លឹមសារក្នុងស្នាដៃបង្ហាញពីទង្វើអហិង្សា គំនិតអហិង្សា មិនបៀតបៀនអ្នកដទៃចង់បានសន្តិភាពក្នុងសង្គម។ ការបណ្តុះគំនិតសន្តិភាពតាមរយៈតួអង្គក្នុងរឿងពុទ្ធនិយមនេះ វាជាបទពិសោធជាការទូន្មាន និងជាគំរូដល់មនុស្សគ្រប់គ្នាសម្រាប់អនុវត្តក្នុងសង្គមគ្រួសារ ឬសង្គមជាតិទាំងមូលនោះនឹងទទួលបាននូវភាពសុខដុម និងសេចក្តីចម្រើនមិនខាន។

ស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមជាគំរូមួយក្នុងការអប់រំមនុស្សឱ្យស្រឡាញ់សន្តិភាព ស្រឡាញ់អំពើល្អ ឱ្យចេះស្គាល់គុណទោស ខ្លាចបាប ឱ្យចេះប្រើបញ្ញាពិចារណាលើហេតុ និងផលជាដើម។

### ខ.៥.៨- ការពង្រឹងអត្តសញ្ញាណមូលដ្ឋានទឹកដី និងបណ្ដុះស្មារតីព្រលឹងជាតិ

ស្នាដៃពុទ្ធនិយមបានឆ្លុះបញ្ចាំងពីព្រលឹងជាតិខ្មែរ។ តើព្រលឹងជាតិខ្មែរនោះមានអ្វីខ្លះ? ហើយព្រលឹងជាតិបានដើរតួនាទីយ៉ាងដូចម្ដេចខ្លះនៅក្នុងជីវិតមនុស្សខ្មែរ? យើងបានដឹងហើយថា ជនជាតិខ្មែរជាជាតិសាសន៍ដ៏ចំណាស់មួយនៅតំបន់អាស៊ីអាគ្នេយ៍យើងនេះ។ នៅក្នុងស្នាដៃពុទ្ធនិយមមានបង្ហាញពីព្រលឹងខ្មែរដែលពាក់ព័ន្ធទៅនឹងព្រលឹងជនជាតិ ព្រលឹងសាសនា ព្រលឹងអត្តសញ្ញាណវប្បធម៌ ព្រលឹងអក្សរសិល្ប៍ និងព្រលឹងទឹកដីព្រៃព្រឹក្សាជាដើម។ តាមរយៈស្នាដៃរឿងទាំងឡាយដែលជាស្នាដៃនិពន្ធដោយកវីខ្មែរគឺពិតជាបានឆ្លុះបញ្ចាំងពីទឹកចិត្តស្នេហាជាតិ ស្នេហាទឹកដី ស្នេហាវប្បធម៌ និងកតញ្ញូក៏ដូចជាការប្រយុទ្ធតស៊ូមិនចេះចប់មិនចេះហើយដើម្បីទឹកដីរបស់ខ្លួន។ អក្សរសិល្ប៍ពុទ្ធនិយមបានបណ្ដុះស្មារតីមនុស្សខ្មែរឱ្យស្រឡាញ់ជាតិ សាសនា និងព្រះមហាក្សត្រ។ ជាពិសេសតាមការសិក្សាអក្សរសិល្ប៍ពុទ្ធនិយមជួយពង្រឹងអត្តសញ្ញាណមូលដ្ឋានដែនដី វប្បធម៌ ប្រវត្តិសាស្ត្រ ឱ្យបានគង់វង្សជាអមតៈស្របដូចពាក្យពោលថា«វប្បធម៌រលត់ជាតិគត់រលាយ វប្បធម៌ពណ្ណរាយជាតិថ្កើងថ្កាន»។

### ខ.៥.៩- អក្សរសិល្ប៍ពុទ្ធនិយម និងសង្គមវប្បធម៌

អក្សរសិល្ប៍ពុទ្ធនិយមជាស្នាដៃដែលបង្កប់តម្លៃសង្គមវប្បធម៌នៅក្នុងនោះផងដែរ។ សង្គមធម៌ដែលមាននៅក្នុងស្នាដៃត្រូវបានប្រជាជនខ្មែរនិយមយកមកបង្ហាញតាមរយៈទំនៀមទម្លាប់ប្រពៃណីរបស់ខ្លួន។

អក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយមមានឥទ្ធិពលលើវិស័យហោរាសាស្ត្រ វិស័យនយោបាយ វិស័យច្បាប់ វិស័យសិល្បៈជាដើម។ ក្នុងវិស័យសិល្បៈត្រូវបានគេយកស្នាដៃរឿងទាំងនោះ ថតជាខ្សែភាពយន្តលេងជាល្ខោនបាសាក់ ល្ខោននិយាយ ល្ខោនស្បែកពណ៌ ល្ខោនស្បែកតូច ចម្រៀង ជាចម្លាក់ ជាសិល្បៈសូនរូប ជាគំនូរជាដើម។ នៅតាមវត្តនីមួយៗឃើញមានរូប ចម្លាក់ព្រះវេស្សន្តរបរាជរថ តាជូជកឡើងដើមឈើមានផ្លែពីរដេញខាំ តាជូជកដឹកដៃនាងអមិត្តជីតាបនា ព្រះសុវណ្ណសាម ព្រះមហោសថនៅតាមទីធ្លាក្នុងវត្តដើម្បីបង្ហាញប្រាប់មនុស្សទូទៅបានយល់ដឹងពីសកម្មភាព និងរូបរាងរបស់តួអង្គនីមួយៗ។ មិនតែប៉ុណ្ណោះនៅតាមវត្តនានាក្នុងព្រះរាជាណាចក្រកម្ពុជាស្ទើរគ្រប់វត្តទាំងអស់សុទ្ធតែមានគំនូររឿងទសជាតកនៅតាមជញ្ជាំងព្រះវិហារ ឬជញ្ជាំងសាលាឆាន់ដើម្បីបង្ហាញពីដំណើរជីវិតផ្សេងៗដែលតួអង្គនីមួយៗបានប្រព្រឹត្តដល់ពុទ្ធបរិស័ទឱ្យបានយល់។ តាមរយៈស្នាដៃអក្សរសិល្ប៍ខ្មែរបែបពុទ្ធនិយម យើងឃើញមានបទពិសោធសម្បូរបែបនៃការផ្ដល់យុត្តិធម៌ក្នុងសង្គមពីសម័យបុរាណគឺផ្អែកលើព្រឹត្តិការណ៍ ឬស្ថានការណ៍ ការអនុវត្ត

តថភាពពិត ហេតុការណ៍ពិតជាក់ស្តែង និងការឱ្យតម្លៃលើហេតុផលដើម្បីវិនិច្ឆ័យទោស។ មនុស្សរស់នៅក្នុងសង្គមតែងត្រូវការយុត្តិធម៌ និងការទទួលបានយុត្តិធម៌ វាជាបញ្ហាដ៏ស្មុគស្មាញបំផុតសម្រាប់បុគ្គល និងសង្គមនីមួយៗ។

សរុបមក ស្នាដៃពុទ្ធនិយមបានលើកតម្លៃសង្គមវប្បធម៌ខ្មែរឱ្យបានរុងរឿងចម្រុងចម្រើន និងសាបព្រោះវប្បធម៌សន្តិភាពដល់ប្រជាពុទ្ធបរិស័ទ។ ព្រោះថាការបង្ហាញពីសកម្មភាពគំរូរបស់តួអង្គព្រះពោធិសត្វបានញុំាងទឹកចិត្តមនុស្សខ្មែរឱ្យកើតមានសេចក្ដីជ្រះថ្លា ខិតខំប្រព្រឹត្តតែសេចក្ដីល្អ តស៊ូនៅក្នុងឆាកជីវិតព្រមទាំងមានសេចក្ដីសង្ឃឹមគ្រប់កាលៈទេសៈ ហើយចេះក្រោកឈរតស៊ូជម្នះរាល់ឧបសគ្គទាំងឡាយ។

### ខ.៥.១០- ការអប់រំឱ្យចូលរួមកសាងសង្គមជាតិ[11]

ស្នាដៃពុទ្ធនិយមជាច្រើនបានធ្វើឱ្យសង្គមនាសម័យកណ្ដាលមានការងើបឡើងពីភក់ជ្រាំ ឬពីការគំរាមកំហែងពីបច្ចាមិត្រ។ ជាពិសេសស្នាដៃទាំងអស់នោះ បានជួយចម្រើនមិនត្រឹមតែផ្នែកស្មារតីនោះទេ ប៉ុន្តែថែមទាំងផ្ដល់ឱ្យយើងនូវការចម្រើនផ្នែកសម្ភារៈថែមទៀតផង។

តាមរយៈប្រវត្តិសាស្ត្រខ្មែរយើងបានសង្កេតឃើញថា បន្ទាប់ពីការធ្លាក់ចុះខ្សោយនៅសម័យក្រោយអង្គរគឺនិន្នាការរបស់សង្គមបានងាកមករកព្រះពុទ្ធសាសនា។ និន្នាការនេះមិនមែនជារឿងដោយចៃដន្យឡើយ ប៉ុន្តែយើងអាចគិតថានេះក៏ព្រោះមនុស្សខ្មែរអាចមានការនឿយណាយនឹងជំនឿបែបព្រាហ្មណ៍និយមដែលដឹកនាំមនុស្សឱ្យជឿទៅលើទេវៈ។ ថ្វីបើខ្មែរងាកមកជឿទៅលើព្រះពុទ្ធសាសនា ប៉ុន្តែប្រជាជនខ្មែរមិនមានគំនិតផ្ដេកផ្ដួលនិយមទៅតាមតែកម្មផលឡើយ។ បានសេចក្ដីថា ប្រជាជនប្រឹងប្រែងរស់ដោយខ្លួនឯង ប្រឹងធ្វើការចិញ្ចឹមជីវិតធ្វើស្រែចម្ការច្បារដំណាំញុំាងឱ្យជីវភាពរបស់ខ្លួនសម្បូរសប្បាយ។ ដោយឡែកទស្សនវិជ្ជាព្រះពុទ្ធសាសនាគ្រាន់តែជាបង្អែមក្លែមជីវិតផ្នែកស្មារតីរបស់ជនជាតិខ្មែរតែប៉ុណ្ណោះ។ ស្មារតីនៃការចូលរួមកសាងសង្គមជាតិតាមរយៈរឿងបែបពុទ្ធនិយមដោយអប់រំមនុស្សឱ្យចេះជួយគ្នាក្នុងគ្រាមានអាសន្នស្របតាមពំនោលពោលថា«ជួយគ្នាក្នុងគ្រាក្រ មិត្តល្អស្គាល់គ្នាក្នុងគ្រាលំបាក»។

---

[11] សិក្សាកថា «តួនាទីអក្សរសិល្ប៍ពុទ្ធនិយមនៅសម័យក្រោយអង្គរ» ឆ្នាំ២០២២

ជាក់ស្តែងដូចជាសម័យបច្ចុប្បន្ន យើងមានកាកបាទក្រហម សមាគមនានាដែលចុះជួយប្រជាជននៅតាមមូលដ្ឋានក្នុងគ្រាលំបាកដូចជាគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត និងប្រធានសក្តិផ្សេងៗដែលកើតឡើងជាយថាហេតុដូចជាការជួយកសាងសាលារៀន មន្ទីរពេទ្យ វត្តអារាម សង់ស្ពាន សង់ផ្លូវថ្នល់ជាដើម ដែលជាប្រយោជន៍សម្រាប់ជាតិ។ ការជួយសង្គ្រោះគ្នាជាកាយវិការដ៏ល្អរបស់ខ្មែរតាំងពីបុរាណមក។ ដោយឡែកនៅសម័យទំនើបនេះវិញ ពិភពលោកទាំងមូលកំពុងប្រឈមនឹងការរីករាលដាលនៃជំងឺកូវីត១៩ ដែលជាជំងឺសាកលនោះ មានប្រទេសជាមិត្តមួយចំនួនបានផ្តល់វ៉ាក់សាំង និងសម្ភារៈបរិក្ខារពេទ្យជាច្រើនជួយដល់កម្ពុជា។

ស្នាដៃពុទ្ធនិយមពិតជាបានចូលរួមលើកកម្ពស់សង្គមខ្មែរឱ្យមានការចែករំលែកគ្នា ជួយគ្នាក្នុងគ្រាលំបាក និងកសាងសង្គមខ្មែរឱ្យមានការរីកលូតលាស់គ្រប់សម័យកាល។

## ច- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌តាមរយៈការយល់ដឹងពីតួនាទី

### ច.១- តួនាទីមាតាបិតា៥យ៉ាង

មាតាបិតាជាមនុស្សសំខាន់នៅក្នុងគ្រួសារ ជាអ្នកដើរតួយ៉ាងសកម្មក្នុងការទទួលខុសត្រូវអប់រំនិងថែទាំកូន ដោយបំពេញនូវកាតព្វកិច្ច ៥ប្រការសម្រាប់សង្គ្រោះបុត្រធីតាគឺៈ

ទី១ៈ តាបិតាគប្បីហាមកូនឱ្យវៀរអំពើបាបក្នុងពេលដែលកូនធ្វើអំពើអាក្រក់ ត្រូវហាមឃាត់កូនយ៉ាងម៉ឺងម៉ាត់ មិនបណ្តែតបណ្តោយឱ្យកូនធ្វើតាមអំពើចិត្តខ្លួននោះឡើយ។

ទី២ៈ ញ៉ាំងកូនឱ្យតម្កល់នៅក្នុងកុសលធម៌ ឱ្យចេះរៀនកាន់រៀនប្រព្រឹត្តអំពើសុចរិតតាមគន្លងធម៌ ពន្យល់អំពីផលនៃការប្រព្រឹត្តល្អឱ្យច្បាស់លាស់ ឱ្យដកចិត្តផ្លាស់ចំណងក្នុងផ្លូវអាក្រក់ ខ្លាចទោសបច្ចុប្បន្ននិងបរលោក។

ទី៣ៈគប្បីអប់រំកូនឱ្យពេញចិត្តក្នុងការសិក្សារៀនសូត្រ មុនដំបូងត្រូវបង្រៀនកូនឱ្យចេះនិយាយសម្តីត្រឹមត្រូវច្បាស់លាស់សមរម្យ ឱ្យស្គាល់ឋានៈស្គាល់វិន័យ វៀរចាកពាក្យអាក្រក់ពាក្យជេរប្រទេចផ្តាសាតាំងពីកូននៅតូចមិនបណ្តោយឱ្យកូនធ្វើអ្វីស្រេចតែអំពើចិត្តឡើយ។

ទី៤៖ រៀបចំគូស្រករទៅតាមប្រពៃណី។ លុះកូនមានវ័យធំល្មមផុតពីការសិក្សាហើយ មាតាបិតាគប្បីរៀបចំឱ្យមានផ្ទះសម្បែងគូស្វាមីភរិយា តាមសេចក្តីស្ម័គ្រចិត្តនៃសាមីរូបទាំងពីរខាងផង តាមគួរដល់ពូជពង្សវង្សត្រកូលនិងទ្រព្យធនជាដើមផង ។

ទី៥៖ចែកទ្រព្យសម្បត្តិឱ្យជាដើមទុន។ លុះរៀបចំកូនហើយ មាតាបិតាគប្បីចែកចាយទ្រព្យសម្បត្តិតាមកម្លាំងធនធាន ទោះទ្រព្យមានវិញ្ញាណក្តី ឥតវិញ្ញាណក្តី ក្នុងនិច្ចសម័យ១ ក្នុងកាលសម័យ១ ដើម្បីជួយបណ្តុះបណ្តាលឱ្យបានកើតកាលវាលគុម្ពក្នុងគ្រួសាររបស់កូនឱ្យហើយជាស្រេច ឱ្យត្រឹមត្រូវតាមលក្ខណៈច្បាប់របស់រដ្ឋ កុំឱ្យកូនមានវិវាទឈ្លោះទាស់ទែងដណ្តើមគ្នាទៅថ្ងៃក្រោយ។

## ច.២- តួនាទីកូនល្អ៥យ៉ាង

កូនប្រុសស្រី កាលណាមាតាបិតាបានបំពេញលក្ខខ័ណ្ឌសព្វគ្រប់ហើយ ត្រូវឆ្លើយតបសេចក្តីល្អរបស់ឪពុកម្តាយដោយកិច្ច ៥យ៉ាងគឺ៖

ទី១៖ ត្រូវចិញ្ចឹមបីបាច់ថែរក្សាមាតាបិតា។ បុត្រធីតាគប្បីសិក្សាថា មាតាបិតាចិញ្ចឹមរក្សាអាត្មាអញហើយអាត្មាអញនឹងចិញ្ចឹមមាតាបិតាវិញដោយទន្ទេញជារឿយៗថា «ធ្វើបុណ្យទាន់ខែភ្លឺ»។ បានន័យថាកូនគប្បីចិញ្ចឹមមាតាបិតាទាន់គាត់នៅមានជីវិតរស់នៅ កុំចាំអស់ពីម៉ែឪទើបធ្វើបុណ្យនោះ។

ទី២៖ ជួយធ្វើការដែលមាតាបិតាត្រូវការ។ បុត្រធីតាគប្បីសិក្សាថា អាត្មាអញនឹងជួយនឹងធ្វើការឱ្យមាតាបិតា ដោយក្តីមិនខ្ជិលច្រអូសឡើយ សេចក្តីខ្ជិលជាអបាយមុខប្រការ១ គឺជាប្រធាននៃសេចក្តីវិនាសនូវប្រយោជន៍គ្រប់យ៉ាងដូច្នេះបើយើងធ្វើការឱ្យអ្នកដទៃ ប៉ុន្តែមិនគួរខ្ជិលធ្វើសេចក្តីល្អដល់ខ្លួនឯងឡើយ។

ទី៣៖ រក្សាកេរ្តិ៍ឈ្មោះលើកតម្កើងពូជពង្សវង្សត្រកូល។ បុត្រធីតាគប្បីសិក្សាថា អាត្មាអញនឹងតម្កើងនូវវង្សត្រកូលឱ្យបានល្អ។ ចរិយាមារយាទ ជារឿងសំខាន់ណាស់ បុត្រធីតាគប្បីរក្សាខ្លួនឯងដោយសីលធម៌ រក្សាសីលជាការធ្វើសេចក្តីល្អដល់ខ្លួនឯង នោះជាធម៌ប្រពៃកន្លង។

ទី៤៖ បម្រើមាតាបិតាដោយសុចរិតឱនលំទោន។ បុត្រធីតាគប្បីសិក្សាថា អាត្មាអញនឹងបដិបត្តិឱ្យបានសមគួរជាអ្នកទទួលនូវទ្រព្យមរតក។ មាតាបិតា ទោះបីជាមានទ្រព្យតិចច្រើនប៉ុណ្ណាៗក្តី គ្មានអ្វីដែលគួរសង្ស័យឡើយ បើថាគាត់កំណាញ់ក៏តែជាមួយនឹងអ្នកដទៃប៉ុណ្ណោះ។ ឯចំណែកខាងកូនរបស់គាត់វិញនោះមានប៉ុន្មានទុកឱ្យទាំងអស់ដោយចិត្តរីករាយកក់ក្តៅជាទីបំផុត។ ដូច្នេះចូរកូនប្រុសស្រីគប្បីធ្វើសេចក្តី

សង្ឃឹមដល់មាតាបិតា ត្រូវខិតខំបដិបត្តិខ្លួនឱ្យរឹងមាំ មានមារយាទល្អសម្តែងនូវការសមគួរជាទីទុកចិត្តដល់មាតាបិតាដាច់ខាតកុំមើលងាយទ្រព្យមរតកនោះឱ្យសោះ។

ទី៥៖ បុត្រធីតាគប្បីសិក្សាថា អាត្មាអញត្រូវធ្វើបុណ្យឧទ្ទិសទក្ខិណាទានដល់មាតាបិតាដែលធ្វើកាលកិរិយាទៅកាន់បរលោក។ កូនៗទាំងឡាយគប្បីធ្វើបុណ្យទានចាត់ចែងតាមប្រពៃណីដល់ម៉ែឪដែលបានលាចាកលោកនេះហើយឱ្យបានសមគួរ។

## ច.៣- តួនាទីស្វាមី៥យ៉ាង

បុរសទាំងឡាយណាដែលទទួលនារីណាមកធ្វើជាភរិយារបស់ខ្លួនហើយ ត្រូវសង្គ្រោះនាងដោយកិច្ច ៥យ៉ាងគឺ៖

ទី១៖ ប្រដៅសព្វសារពើ ពោលពាក្យពីរោះសរសើរដោយលក្ខណៈប្រព្រឹត្តជាប្រយោជន៍ដល់ភរិយា។ ស្រឡាញ់រាប់អានថាជាភរិយា យើងជាស្វាមីរបស់ស្ត្រីណា គប្បីសង្គ្រោះស្ត្រីនោះដោយទំនុកបម្រុងគ្រឿងប្រើប្រាស់មិនឱ្យខ្វះខាតបានដល់សម្លៀកបំពាក់ជាដើម។

ទី២៖ មិនមើលងាយ ជេរវាយភរិយា ដូចទាសាទាសី កម្មករឡើយ។ មិនត្រូវប្រមាទមើលងាយដូចជាខ្ញុំកំដរ "បាវព្រាវ" ការនិយាយចំពោះភរិយា គប្បីប្រើពាក្យសម្តីផ្អែមល្ហែមពិរោះពិសាមិនពោលពាក្យពោយរាយឥតប្រយោជន៍ ភរិយាមានកំហុសបន្តិចបន្តួចក៏គួរអត់ឱនឱ្យ ហើយទូន្មានដោយសេចក្តីល្អ។

ទី៣៖ មិនប្រព្រឹត្តកន្លងភរិយា មិនត្រូវប្រព្រឹត្តគំនិតក្បត់ព្រំដែនជាប្តីយកកំពូលស្នេហារបស់ខ្លួនទៅបូជាដល់ស្ត្រីដែលមិនមែនជាកម្មសិទ្ធិនៃភរិយាត្រូវប្រកាន់ខ្ជាប់នូវនាទីថាជាស្វាមីរបស់គេដោយពិត ។

ទី៤៖ ប្រគល់នូវរបស់របរទាំងពួងឱ្យមានឥស្សរភាពដល់ភរិយា ប្រគល់អំណាចឱ្យជាធំជាស្ត្រីមេផ្ទះជាស្ត្រីរៀបចំទុកដាក់ទ្រព្យសម្បត្តិរក្សាថែទាំលម្អគេហដ្ឋាន ព្រោះភរិយាទុកជានាយកស្តីទីខាងក្រសួងបោសសម្អាតលំនៅឋានសមនឹងស្លោកថា៖ «ទ្រព្យគង់ត្បិតស្រី ចេះសំចៃទុក មានផ្ទះស្រណុក ត្បិតភរិយាជា»។

ទី៥៖ស្វាមីគប្បីរៀបចំឱ្យមានអលង្ការដល់ភរិយាសម្រាប់ប្រើប្រាស់គ្រប់គ្រាន់តាមកាលៈទេសៈនិងសម័យនិយម។ រីឯភរិយាយ៉ាងល្អឯកគាប់ភ្នែកខ្លួនឯង និងអ្នកផងបុរសស្វាមីត្រូវឃុំគ្រងកុំបីរំលងការរក្សា។

### ច.៤- តួនាទីភរិយា៥យ៉ាង

ភរិយាត្រូវគោរពប្រតិបត្តិស្វាមីដោយកិច្ច ៥យ៉ាងគឺ៖

ទី១៖ ចាត់ចែងការងារផ្ទះដោយផ្ចិតផ្ចង់។ ភរិយាគប្បីចាត់ចែងការងារមានម្ហូបចំណីជាដើមដោយផ្ចិតផ្ចង់សម្រាប់ស្វាមីឱ្យបានត្រឹមត្រូវតាមពេលវេលា ។

ទី២៖ សង្គ្រោះញាតិខាងស្វាមី និងខាងខ្លួនឯងដោយប្រពៃ។ ត្រូវមានចិត្តស្មើមិនត្រូវលម្អៀងម្ខាងៗឡើយ ហើយព្យាយាមជួយគ្នាតាមការគួរ ។

ទី៣៖ គប្បីថែទាំទ្រព្យសម្បត្តិដែលប្តីរកបានមិនឱ្យវិនាសខូចខាតបាត់បង់ដោយការមិនគួរ។

ទី៤៖ មិនប្រព្រឹត្តកន្លងចិត្តប្តី គឺមិនត្រូវយកកំពូលស្នេហាទៅប្រគល់ឱ្យបុរសដទៃក្រៅពីស្វាមីខ្លួនឡើយ។

ទី៥៖ភរិយាគប្បីឈ្លាសវៃក្នុងការងារទាំងឡាយរបស់ស្ត្រីមិនត្រូវខ្ជិលច្រអូសកិច្ចការណាមិនទាន់បានសម្រេចត្រូវប្រញាប់វាសវៃធ្វើបង្ហើយ ពន្យារពេលថាថ្ងៃនោះ «ធ្វើអ្វីធ្វើឱ្យហើយ កុំទុកឡើយបន្សល់កេរ»។

នាទីស្វាមីភរិយា ប្រាំៗដូចគ្នាធម៌សង្គ្រោះសម្រាប់ឱ្យយើងកាន់រួមរស់សន្តោសដល់គ្នាជាប្រក្រតី។

### ច.៥- តួនាទីគ្រូបាអាចារ្យ៥យ៉ាង

នាទីគ្រូអាចារ្យដែលត្រូវបំពេញដល់សិស្សមាន ៥យ៉ាងគឺ៖

ទី១៖ ដឹកនាំសិស្សឱ្យល្អដោយសុទ្ធចិត្ត។ គ្រូគប្បីទូន្មានសិស្សឱ្យបានបទល្អឱ្យចេះប្រើឥរិយាបទទាំង៤ គឺដេក ដើរ ឈរ អង្គុយ ជាដើមឱ្យមានរបៀបរៀបរយសមរម្យល្អក្នុងទីប្រជុំជន មិនឱ្យផ្តាំឆ្គងនិងភ្នែកអ្នកដទៃ។

ទី២៖ បង្ហាត់បង្រៀនសិស្សដោយល្អញុំាងសិស្សឱ្យរៀនល្អគឺបង្ហាត់បង្រៀននូវអត្ថ និងព្យញ្ជនៈឱ្យបានត្រឹមត្រូវចេះប្រើរបៀបសេចក្តីរៀបពាក្យអធិប្បាយពន្យល់ហេតុផលឱ្យចូលចិត្តយល់បានពិតប្រាកដ។

ទី៣៖ គ្រូអាចារ្យគប្បីបង្ហាត់សិល្បវិទ្យាឱ្យអស់ចំណេះ មិនលាក់ទុក មានមកប៉ុន្មានក៏បង្ហាត់បង្រៀនសិស្សឱ្យអស់តាមចំណេះវិជ្ជាចេះចាំរបស់ខ្លួន ដោយមានឆន្ទៈដ៏ល្អគឺចង់ឱ្យសិស្សចេះចាំដូចខ្លួន ឬលើសទៅទៀតរឹតតែប្រសើរ។

ទី៤៖ លើកតម្កើងសិស្សក្នុងទីប្រជុំ បើយល់ឃើញថាសិស្សណាមួយមានចំណេះវិជ្ជា មានចរិយាសណ្ដាប់ធ្នាប់សមរម្យល្អ គួរយកគុណសម្បត្តិនោះមកបង្ហាញសរសើរក្នុងទីចំពោះមុខមិត្តភក្តិជាសម្លាញ់របស់ខ្លួនដើម្បីឱ្យមិត្តរបស់ខ្លួនមានសេចក្ដីទុកចិត្តស្និទ្ធស្នាលរាប់អាន និងការទំនុកបម្រុងដល់សិស្ស។

ទី៥៖ ធ្វើសេចក្ដីការពារសិស្សគ្រប់ទិសទាំងឡាយ បើសិស្សទៅទីណាមិនឱ្យលំបាកដូចជាការចេញទៅរៀនសូត្រចំណេះវិជ្ជា ផ្លូវលោក ផ្លូវធម៌ជាដើម ចេះពន្យល់ណែនាំហេតុផលឱ្យយល់ពីប្រយោជន៍នៃការសិក្សាទាល់តែសិស្សមានចិត្តជ្រះថ្លាព្យាយាមក្នុងការសិក្សាហើយ ត្រូវជួយទំនុកបម្រុងសិស្សដោយគ្រឿងសិក្សាតាមបានល្មមឱ្យសិស្សមានសេចក្ដីរីករាយស្រឡាញ់ពេញចិត្តក្នុងការសិក្សា។

### ច.៦- តួនាទីសិស្ស៥យ៉ាង

សិស្សមានតួនាទី ៥យ៉ាងដែលត្រូវគោរពប្រតិបត្តិគ្រូអាចារ្យគឺ៖

ទី១៖ ក្រោកឈរទទួលក្នុងវេលាដែលគ្រូបាអាចារ្យដើរមកគឺថាបើខ្លួនអង្គុយក្នុងទីកន្លែងណាមួយហើយស្រាប់តែគ្រូធ្វើដំណើរមកកាន់ទីកន្លែងនោះ យើងត្រូវក្រោកឈរឡើងដោយគោរព។

ទី២៖ គាល់បម្រើគ្រូអាចារ្យដោយចិត្តស្មោះសរ។ ចូលទៅចាំបម្រើលោកបម្រើព្រឹកល្ងាចនោះបានការរៀបចំគ្រឿងចង្ហាន់ ពុំនោះសោតប្រសិនបើលោកមានការរវល់អ្វី សិស្សមិនត្រូវព្រងើយកន្តើយគេចវេះដោះដៃឡើយត្រូវតែជួយបំពេញធុរៈនោះឱ្យបានសម្រេច។

ទី៣៖ជឿស្ដាប់ឱវាទលោកទូន្មានប្រៀនប្រដៅដោយល្អចំពោះបញ្ហាណាមួយ យើងគួរគូសចំណាំក្នុងចិត្ត ហើយត្រូវត្រិះរិះមើលផងបើឃើញថាត្រូវល្អប្រញាប់ប្រតិបត្តិធ្វើតាម។ គតិភាសិតក៏បានបញ្ជាក់ប្រាប់យើងថា៖ "ពុតគ្រូកុំគ្រាប់ ច្បាប់គ្រូឱ្យយក"។

ទី៤៖ ប្រណិប័តន៍ដោយធ្វើការងារជួយគ្រូអាចារ្យ។ សិស្សត្រូវយកចិត្តទុកដាក់បម្រើគ្រូ ធ្វើវត្តប្រតិបត្តិដូចជាសិស្សដែលនៅក្នុងសម្នាក់គ្រូត្រូវឧស្សាហ៍បោសសម្អាតកន្លែងរៀន ឬផ្ទះទីកន្លែងនៅ និងគក់

ប្រាប់ជាដើម។ សិស្សគប្បីសិក្សាថាការប្រតិបត្តិគ្រូដោយធ្វើការងារទោះបីការងារនោះតូចតាចបន្តិចក៏ដោយក៏មិនត្រូវឱ្យលោកគ្រូអាចារ្យធ្វើខ្លួនឯងដែរ។

ទី៥៖ សិស្សគប្បីសិក្សាថា អាត្មាអញត្រូវរៀនសិល្បវិជ្ជាអំពីលោកគ្រូអាចារ្យដោយសេចក្តីគោរព។ មិនចំពោះតែវិជ្ជាអ្វីនោះ បើសិស្សមានសមត្ថភាពរៀនបានច្រើនមុខវិជ្ជាគឺរឹតតែល្អ ទោសរបស់មុខវិជ្ជានៅលើអ្នកប្រើជាសំខាន់ បើប្រើក្នុងផ្លូវត្រូវគឺជាគុណ តែបើប្រើក្នុងផ្លូវខុសគឺជាទោស។ ការប្រកបនូវមុខវិជ្ជាអ្វីមួយដើម្បីចិញ្ចឹមជីវិតក្តីដើម្បីជាប្រយោជន៍ដល់សង្គមជាតិក្តី ត្រូវមើលឆន្ទៈខ្លួនឯងឱ្យជាក់ច្បាស់ ព្រោះឆន្ទៈគឺសេចក្តីពេញចិត្តក្នុងការងារជាកម្លាំងអាចញ៉ាំងសេចក្តីព្យាយាមឱ្យប្រព្រឹត្តជាប់មិនដាច់ជាហេតុឱ្យសម្រេចនូវប្រយោជន៍ បើមិនដូច្នេះវាជួបប្រទះនូវការឥតប្រយោជន៍អស់ទាំងក្នុងរឿងផ្សេងៗទៀតផង។

## ច.៧- តួនាទីចៅហ្វាយនាយ៥យ៉ាង

ចៅហ្វាយនាយក៏ត្រូវមានចិត្តករុណាសន្ដោសសង្គ្រោះដល់កម្មករកិច្ច៥យ៉ាងគឺ៖

ទី១៖ ចាត់ចែងការងារឱ្យធ្វើតាមសមគួរដល់កម្លាំង ចៅហ្វាយនាយកាលបើប្រើទាសៈ "កម្មករ" ឱ្យធ្វើការណាមួយគប្បីប្រមើលមើលសមត្ថភាពគ្នាសិនបើទាសៈនោះមានប្រាជ្ញាស្មារតីមានកម្លាំងមាំមួនល្មមទទួលការងារចង្អៀត ការងារធ្ងន់ៗទៅបានទើបចាត់ចែងឱ្យធ្វើតាមសមគួរនៃសមត្ថភាព។

ទី២៖ ឱ្យភោជនាហារ និងថ្លៃឈ្នួល និងរង្វាន់ដោយត្រឹមត្រូវដល់អ្នកបម្រើ ។ ចៅហ្វាយនាយគប្បីទំនុកបម្រុងខាងភោជនាហារសម្រាប់កម្មករបរិភោគឱ្យបានគ្រប់គ្រាន់តាមពេលវេលាមិនឱ្យខ្វះខាត។ កាលណាចៅហ្វាយនាយមានចិត្តល្អ ចេះចែករំលែក ចេះចែកគ្នារស់ នោះកូនចៅក្រោមបង្គាប់ក៏មានចិត្តគោរពស្រឡាញ់ក្រោមអំណាចនៃបុណ្យបារមី និងសន្តានចិត្តមេត្តារបស់ខ្លួនវិញផងដែរ។

ទី៣៖ ព្យាបាលក្នុងវេលាមានជំងឺ កាលបើកម្មករមានជំងឺតម្កាត់កើតឡើង ចៅហ្វាយត្រូវប្រញាប់ប្រញាល់ទិញថ្នាំព្យាបាលពេគថែទាំរក្សាជំងឺកម្មករឱ្យទាល់តែជាសះស្បើយ។ ការយកចិត្តទុកដាក់របស់ចៅហ្វាយនាយចំពោះកូនចៅជាគុណធម៌ដ៏ប្រសើរណាស់ដែលបុគ្គលគ្រប់រូបគប្បីយកតម្រាប់តាម។

ទី៤៖ ចែកភោជនាហារដែលមានឱជារសប្លែកៗឱ្យបរិភោគភោជនាហារគាប់ប្រសើរប្លែកៗ ជួនមានម្តងម្កាល ចៅហ្វាយនាយគួរតែចែករំលែកដល់កម្មករឱ្យបានបរិភោគខ្លះៗផងវត្ថុទាំងនេះទុកជាទិព្វមន្តពិសេសសម្រាប់លើកកម្លាំងចិត្តកម្មករឱ្យស្រឡាញ់ការងាររបស់យើង ។

ទី៥៖ បើកឱ្យសប្បាយក្នុងការគួរដូចជាមានពិធីបុណ្យអ្វីមួយមានល្បែងមហោស្រព ឬក្នុងពេលបុណ្យចូលឆ្នាំជាដើម ចៅហ្វាយនាយត្រូវបើកឱកាសឱ្យកម្មករបានទៅលេងសប្បាយនឹងគេ និងបើករង្វាន់ប្រាក់កាសសម្រាប់ចាយវាយក្រៅខ្លះផង ចេះសម្ដែងទឹកចិត្តរីករាយចំពោះកម្មករឱ្យគ្នាសប្បាយចិត្ត មិនធុញទ្រាន់នឹងយើងជាចៅហ្វាយនាយ។ បើចង់ឱ្យគេស្រឡាញ់យើង យើងសម្ដែងទឹកមុខរីករាយ គេមិនសប្បាយចិត្តនឹងយើងពាក់មុខយក្ខដាក់គេទេ ។

## ច.៨- តួនាទីទាសកម្មករ ឬអ្នកបម្រើការ៥យ៉ាង

ទាសកម្មករត្រូវប្រតិបត្តិនាទីរបស់ខ្លួនមាន ៥យ៉ាងគឺ៖

ទី១៖ ក្រោកឡើងធ្វើការមុនចៅហ្វាយនាយ កិច្ចការដែលចៅហ្វាយនាយដែលចាត់ចែងឱ្យធ្វើនោះត្រូវស្ទុះស្ទាប្រញាប់ប្រញាល់ធ្វើឱ្យបានមុនៗចៅហ្វាយនាយ ។

ទី២៖ លែងធ្វើការងារក្រោយចៅហ្វាយនាយ កិច្ចការរបស់ចៅហ្វាយនាយត្រូវធ្វើឱ្យដល់ទីបំផុតដល់ពេលវេលាមិនត្រូវឈប់ក្នុងពេលវេលាចាំចៅហ្វាយនាយឈប់ចាំឈប់តាមជាដំណឹង។

ទី៣៖កាន់យកតែរបស់ណាដែលចៅហ្វាយនាយឱ្យប៉ុណ្ណោះត្រូវមានសច្ចៈទៀងត្រង់នឹងចៅហ្វាយនាយរបស់ខ្លួនមិនត្រូវមានចិត្តគំនិតប្រព្រឹត្តលួចលាក់របស់ចៅហ្វាយនាយឡើយ។

ទី៤៖ ធ្វើការងារដោយយកចិត្តទុកដាក់ពោលគឺធ្វើការងារឱ្យបានល្អ។ ការងារណាដែលចៅហ្វាយនាយបញ្ជាឱ្យធ្វើត្រូវមានឆន្ទៈខំប្រឹងប្រែងធ្វើមិនធុញទ្រាន់មិនខ្ជីខ្ជាធ្វើឱ្យតែរួចពីដៃ ចេះសម្អាតដូចជារបស់ខ្លួនធ្វើទាល់តែបានសម្រេចជាបំផុត។

ទី៥៖ នាំកិត្តិគុណចៅហ្វាយនាយទៅពោលសរសើរក្នុងទីដទៃ កិត្តិគុណ គឺគុណសម្បត្តិ ចរិយាសម្បត្តិ សុភាពស្លូតបូតទៀងត្រង់ ឬគុណសម្បត្តិដែលល្បីខ្ចរខ្ចារ។

បណ្ដាកិច្ចទាំងឡាយសម្រាប់សង្គមគ្រួសារគឺមាតាបិតាសង្គ្រោះដល់បុត្រធីតាៗតបស្នងសងគុណមាតាបិតា ស្វាមីសង្គ្រោះដល់ភរិយាៗចេះប្រតិបត្តិស្វាមី គ្រូសង្គ្រោះដល់សិស្សៗចេះគោរពប្រតិបត្តិចំពោះគ្រូ ចៅហ្វាយនាយសង្គ្រោះដល់ទាសកម្មករ ទាសកម្មករប្រតិបត្តិចំពោះចៅហ្វាយនាយ តាមកិច្ចដែលត្រូវសង្គ្រោះគ្នាទៅវិញទៅមក។

### ច.៩- តួនាទីមិត្តល្អ៥យ៉ាង

ទី១៖ ឱ្យនូវអ្វីដែលគួរឱ្យដល់មិត្តសម្លាញ់។ មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវធ្វើទានគឺអ្វីដែលគួរធ្វើឱ្យដល់មិត្តសម្លាញ់។

ទី២៖ មិត្តល្អគប្បីសិក្សាថា អាត្មាអញគប្បីនិយាយពីរោះ មិនទ្រគោះគំរោះគំរើយទៅរកមិត្តសម្លាញ់ខ្លួនឡើយ។

ទី៣៖ មិត្តល្អគប្បីសិក្សាថា អាត្មាអញត្រូវធ្វើប្រយោជន៍ដល់មិត្ត។

ទី៤៖ មិត្តល្អគប្បីសិក្សាថាអាត្មាអញត្រូវសង្គ្រោះមិត្តសម្លាញ់ដោយមិនលើកតម្កើងខ្លួនគឺត្រូវធ្វើជាមនុស្សប្រកបដោយចរិយាមារយាទថ្លៃថ្នូរ។

ទី៥៖ មិត្តល្អគប្បីសិក្សាថា អាត្មាអញមិននិយាយបោកបញ្ឆោតដោយការនិយាយកុហកឱ្យខុសអំពីសេចក្ដីពិតដល់មិត្តសម្លាញ់ឡើយ។ វាចាមាន៣យ៉ាងគឺវាចាលាមក១ វាចាផ្កា១ វាចាទឹកឃ្មុំ១។ វាចាលាមកបានដល់ការនិយាយកុហក វាចាផ្កាបានដល់ការមិននិយាយកុហក វាចាទឹកឃ្មុំបានដល់ការនិយាយពីរោះមានប្រយោជន៍។ ដូច្នេះមនុស្សល្អគប្បីសិក្សាថា អាត្មាអញមិនគួរពោលពាក្យកុហកឡើយ[12]។

## II.៣.២-តើព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ដូចម្ដេចខ្លះ?

### ក- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌បុគ្គល

ព្រះពុទ្ធសាសនាបានលើកកម្ពស់ការអប់រំផ្នែកចរិយាធម៌បុគ្គល ដោយឱ្យបុគ្គលមានការប្រព្រឹត្តបានត្រឹមត្រូវ និងប្រកបដោយសេចក្ដីសុខគ្រប់ប្រការ។ ការអប់រំឱ្យមានការប្រព្រឹត្តបានល្អប្រពៃ ចេះស្គាល់អំពើបាប និងស្អប់ខ្ពើមអំពើបាបដែលទាំងអស់នេះជាវិការៈនៃគោលធម៌របស់ព្រះសម្មាសម្ពុទ្ធ។

ដាក់ស្តែងបុគ្គលអាចជម្រះចិត្តសៅហ្មងជម្រុះចោលនូវគ្រឿងហ្មងសៅទាំងឡាយ ចាប់យកតែសេចក្ដីល្អគ្រប់យ៉ាងដើម្បីសម្រេចបាននូវភាពដ៏ត្រឹមត្រូវនៃជីវិត។ កាលណាមនុស្សមានចិត្តសៅហ្មងហើយនោះនាំឱ្យគេមានចិត្តមិនសូវស្រឡះស្រឡាំធ្វើការអ្វីមិនជ្រះស្រឡះដែលជាហេតុនាំឱ្យមានទុក្ខសោកនៅក្នុងផ្លូវជីវិត។ បន្ថែមពីនេះ ការមិនយល់អ្វីទាំងនោះនាំឱ្យមានផលរមាស់ជួបសេចក្ដីលំបាកកាយចិត្ត មិន

[12] https://5000-years.org/kh/read/1404

មានភាពជ្រះស្រឡះ ហើយធ្វើអ្វីៗទាំងប្រថុយប្រថាន។ ចរិយាធម៌បុគ្គលបានដល់ការប្រព្រឹត្តល្អជាចរិយាសាស្ត្ររបស់មនុស្សប្រុសស្រីគប្បីប្រកាន់យកដើម្បីក្លាយជាឧត្តមបុគ្គល។ ព្រះសង្ឃបានជួយណែនាំដាស់តឿនបុគ្គលឱ្យជម្រុះចោលនូវគ្រឿងសៅហ្មងទាំងឡាយឈោងចាប់តែភាពត្រឹមត្រូវ និងប្រកបដោយមេត្តាធម៌ជាគោល។ ចរិយាមារយាទ ការប្រព្រឹត្តបានល្អប្រពៃ ដេក ដើរ ឈរ អង្គុយ មានការពោលនិយាយស្តីត្រូវតាមវេលាវិកាលជាដើម។ ទាំងអស់នេះជាការអប់រំក្នុងព្រះពុទ្ធសាសនាត្រង់សិក្ខាបទនៃការនិយាយស្តីពីពេះកុំពោលពាក្យញុះញង់ចាក់ដោយរុកកួនគេដែលជាទោសគ្រប់យ៉ាង។ ព្រះពុទ្ធទ្រង់ប្រដៅមនុស្សលោកឱ្យស្គាល់កាលវេលានិយាយស្តីឱ្យត្រូវកាលវេលាមិនត្រូវនិយាយដោយគ្មានការពិចារណានោះទេ។ ប្រសិនបើកាលណាប្រព្រឹត្តខុសពីនេះ នោះអាចនាំទុក្ខទោសដល់យើងបាន។ ព្រះសាស្តាលោកណែនាំឱ្យដើរផ្លូវកណ្តាលដែលជាមាគ៌ាដ៏ប្រសើរ។ ជាបុគ្គលល្អពេញដោយចរិយាសម្បត្តិត្រូវមានរូបសម្បត្តិផង និងចិត្តគំនិតល្អប្រពៃ ហើយជាទីទុកចិត្តពីមនុស្សជុំវិញ។ ព្រះពុទ្ធលោកណែនាំឱ្យចៀសឱ្យឆ្ងាយពីអបាយមុខកុំចូលចិត្តគ្រឿងសប្បាយភ្លេចខ្លួន ពោលគឺណែនាំឱ្យស្គាល់ប្រមាណជាមនុស្ស។ ទោះបីជាការរស់នៅឱ្យមានអនាម័យ ការហូបចុកឱ្យដឹងប្រមាណ និងទៅណាមកណាឱ្យស្គាល់កាលវេលាជាដើម។ ជាពិសេសឱ្យស្គាល់តម្លៃខ្លួនជានិច្ច។ ការអប់រំចរិយាធម៌នោះរួមមាន ការអប់រំផ្លូវចិត្ត អប់រំសីលធម៌ចរិយាធម៌ដើម្បីឱ្យមនុស្សមានការរស់នៅប្រកបដោយសុវត្ថិភាព និងសន្តិភាពសង្គម។ លើសពីនេះព្រះពុទ្ធសាសនាបានកសាងធនធានមនុស្ស ផ្តល់ចំណេះដឹងបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ចែករំលែកផ្សព្វផ្សាយពុទ្ធឱវាទ និងចែករំលែកបទពិសោធល្អៗជាចរិយាធម៌ដ៏ប្រពៃ។ ព្រះពុទ្ធសាសនាបានចូលរួមកសាងរចនាសម្ព័ន្ធរួមមានវត្តអារាម មន្ទីរពេទ្យ សាលារៀន ស្ពាន ថ្នល់ អូរប្រឡាយ និងសាលាឆទានជាដើមបម្រើដល់ប្រជាពុទ្ធបរិស័ទពិតៗ។ ក្រៅពីនេះចូលរួមកសាងក្នុងវិស័យសង្គមកិច្ច សង្គ្រោះកុមារអនាថា ទុរគតជន មនុស្សទីទ័លក្រគ្មានទីពឹងចាស់ជរា។ ជាមួយគ្នានេះ ព្រះពុទ្ធសាសនាមានតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការអប់រំសីលធម៌ ចរិយាធម៌ក្នុងការកសាងសង្គមជាតិទាំងមូល។ ម្យ៉ាងវិញទៀត កាលណាសង្គមមួយមានការគោរពសីលធម៌ព្រះពុទ្ធសាសនាបានល្អធ្វើឱ្យវិស័យព្រះពុទ្ធសាសនាមានភាពរីកចម្រើន ស័ក្តិសមជាទីគោរពបូជារបស់ពុទ្ធបរិស័ទ និងពង្រឹងគុណភាពពុទ្ធិកសិក្សាដើម្បីអភិវឌ្ឍធនធានបព្វជិតឱ្យកាន់តែមានសុក្រឹតភាព និងមានគុណភាពខ្ពស់។ ព្រះពុទ្ធសាសនាជាកម្លាំងដឹកនាំចរិយាធម៌សង្គមដែលមានពុទ្ធសាសនិកជនទាំងបព្វជិតទាំងគ្រហស្ថដែលបានខិតខំប្រណិប័តន៍ខ្លួនឯងផងជួយអប់រំពុទ្ធបរិស័ទផង សមស្របតាមលំអានខ្លឹមសារក្នុងព្រះត្រៃបិដកដែលជាព្រះធម៌របស់ព្រះសម្មាសម្ពុទ្ធនៃយើង។

តាមរយៈរឿងទុំទាវបានលាតត្រដាងពីឱវាទព្រះពុទ្ធសាសនាផងដែរ។ នៅពេលដែលនេនទុំចេញទៅលក់តោកឯខេត្តត្បូងឃ្មុំ នៅគ្រានោះនេនពេជ្របានពោលរំលឹកសាមណេរទុំថា[13] «បើដើរមានប្អូនខ្លួនជាសង្ឃ ទើបបានត្រូវត្រង់ឥតមានមោះ បើដើរទៅក្តីបាសកសោះ កេរ្តិ៍កោះថ្លោះធ្លោយឱ្យមានប្រាំ»។ ន័យត្រង់នេះជាការដាស់សតិមួយថា បើជាព្រះភិក្ខុសង្ឃគប្បីប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវសិក្ខាបទខ្លួនជាសង្ឃ។ រីឯមនុស្សសាមញ្ញវិញគប្បីប្រកាន់ឱ្យបានខ្ជាប់ខ្ជួននូវនិច្ចសីល ឬសីលប្រាំដែលជាធម៌មួយប្រដៅបុគ្គលឱ្យបានល្អប្រសើរចៀសឱ្យឆ្ងាយពីគ្រឿងសៅហ្មងទាំងឡាយ។

សរុបមក ព្រះពុទ្ធសាសនាបានអប់រំចរិយាធម៌បុគ្គលឱ្យចេះទម្លាប់ខ្លួនក្នុងការរស់នៅឱ្យបានល្អប្រសើរ កុំឱ្យមានអភិភាព ឬភាពអប្រិយដែលកើតឡើងដោយសារតែទង្វើឆ្គាំឆ្គងទាំងពួង។

## ខ- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ក្នុងគ្រួសារ

ព្រះពុទ្ធសាសនាជួយលើកកម្ពស់ការអប់រំចរិយាធម៌ក្នុងគ្រួសារដូចជាជួយឱ្យជីវិតប្តីប្រពន្ធមានធម៌មេត្តាដល់គ្នានឹងគ្នា ចេះស្រឡាញ់គ្នា និងចេះអធ្យាស្រ័យគ្នាទៅវិញទៅមក។ ជាការពិតណាស់ថា ព្រះពុទ្ធបានដាស់តឿនឱ្យប្តីនិងប្រពន្ធគប្បីមានសង្គហធម៌ ពោលគឺធម៌សង្គ្រោះដល់គ្នាទៅវិញទៅមក។ កាលណាប្តីនិងប្រពន្ធមានធម៌សង្គ្រោះទាំងអស់នេះ នោះគេអាចដឹកនាំគ្រួសារនេះឆ្ពោះទៅរកភាពរីកចម្រើនរុងរឿនរស់នៅប្រកបដោយសេចក្តីសុខសុភមង្គល។ នៅក្នុងសង្គមខ្មែរកាលពីសម័យបុរាណនាសម័យលង្វែក ខ្មែរមានទំនៀមមួយគឺកូនប្រុសតម្រូវឱ្យបួសរៀននៅក្នុងសម្នាក់ព្រះពុទ្ធសាសនា ហើយកូនស្រីតម្រូវឱ្យចូលម្លប់ដើម្បីសិក្សាពីចរិយាសាស្ត្រស្ត្រីមេផ្ទះជាដើម។ នៅក្នុងនោះក្បួនចរិយាសាស្ត្រនេះកត់សម្គាល់យ៉ាងខ្លាំងគឺថា កូនប្រុសត្រូវបួសរៀនដើម្បីសិក្សារៀនសូត្រវិន័យធម៌អាថ៌ គម្ពីរព្រះត្រៃបិដក និងជំនាញផ្សេងៗ។ ជាប្រយោជន៍ថា នៅពេលសឹកមកវិញគឺមានវិជ្ជាអាចចិញ្ចឹមជីវិត និងអាចចិញ្ចឹមប្រពន្ធកូនបានដោយស្រួល។ ត្បិតថា នៅពេលដែលបួសរៀននៅក្នុងសម្នាក់ព្រះពុទ្ធសាសនាមិនមែនរៀនតែគម្ពីរនោះទេ គេតម្រូវឱ្យរៀនអក្សរសាស្ត្រ គណិតសាស្ត្រ ក្បួនលេខនព្វន្ត ជំនាញដូចជាស្ទូត្រ ឈូសឈើ ចម្លាក់ជាងសូនរូបជាដើម។ រីឯកូនស្រីវិញ គេតម្រូវឱ្យរៀនចរិយាសាស្ត្រស្ត្រីរួមមានវិជ្ជាមេផ្ទះ ក្បួនច្បាប់ស្រីការប្រព្រឹត្ត ចរិយាមារយាទដែលមានចែងក្នុងច្បាប់ស្រី។

[13] រឿងទុំទាវ, ព្រះភិក្ខុសោម ឆ្នាំ១៩១៥

សរុបមក ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌សំខាន់ណាស់នៅក្នុងគ្រួសារដែលមានគោលបំណងសំខាន់គឺសុខដុមរមនានៅក្នុងសង្គមគ្រួសារ។

## គ- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ក្នុងសង្គមជាតិ

ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ក្នុងសង្គមជាតិយើងឱ្យបានរីកចម្រើនលើគ្រប់វិស័យទៅតាមបែបផែននីមួយៗ។ ចរិយាធម៌បានដល់ការប្រព្រឹត្តដោយសេចក្តីល្អមានបែបបទចរិយាមារយាទល្អប្រពៃ និងប្រកបដោយគុណធម៌។ យ៉ាងណាមិញ នៅក្នុងសង្គមជាតិទាមទារឱ្យមានការចូលរួមពីសម្នាក់ព្រះពុទ្ធសាសនា។ ទីវត្តអារាមជាទីជំរកអប់រំចរិយាធម៌ដល់ពុទ្ធបរិស័ទ និងយុវជនដែលជាទំពាំងស្នងឬស្សីដើម្បីថែរក្សាការពារ សុខសន្តិភាព សេចក្តីសុខសាន្តដល់សង្គមជាតិដោយប្រកាន់យកព្រះពុទ្ធឱវាទជាប្រទីបបំភ្លឺផ្លូវក្នុងការអប់រំសីលធម៌ ចរិយាធម៌ សេចក្តីថ្លៃថ្នូរដើម្បីលុបបំបាត់អំពើហិង្សាគ្រួសារ និងសង្គមជាតិ។ ប្រទេសកម្ពុជាមានសុខសន្តិភាពពេញលេញទាំងវិស័យពុទ្ធចក្រ និងអាណាចក្រ និងមានការអភិវឌ្ឍរីកចម្រើនទន្ទឹមគ្នា។ ហេតុនេះពុទ្ធបរិស័ទដែលមានជីវភាពធូរធារមានសិទ្ធិគោរពជំនឿសាសនារៀងៗខ្លួន។ ជាពិសេសប្រទេសកម្ពុជាព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ [14] ។ ទស្សនាទានព្រះពុទ្ធសាសនាពេលនេះ ពិតជាមានតម្លៃណាស់ដែលបានបញ្ជាក់ឱ្យច្បាស់ថា នេះជាចំណែកមួយជួយដល់សិស្សានុសិស្សឱ្យទទួលបាននូវការអប់រំមួយទៀតខាងផ្នែកផ្លូវចិត្ត បន្ទាប់ពីអប់រំនៅសាលារៀនលើចំណេះដឹងទូទៅឱ្យប្រព្រឹត្តអំពើល្អដែលជាកុសលក្នុងផ្លូវដែលសង្គមត្រូវការ និងបានជៀសឆ្ងាយពីការយល់ខុសផ្សេងៗទៀត។ កម្មវិធីទស្សនាទាន ព្រះពុទ្ធសាសនានេះ មានសារៈសំខាន់ណាស់ដែលអាចជួយឱ្យសិស្សបានយល់ដឹងពីតម្លៃពិតនៃការរៀនសូត្រ។ តាមរយៈអប់រំតាមផ្លូវពុទ្ធសានានេះដែរក៏ជួយតម្រង់ទិសឱ្យសិស្សដែលបោះបង់ការសិក្សាដោយប្រការផ្សេងៗដោយមិនដឹងខ្លួនដូចជា ការសេពគ្រឿងញៀន ឬល្បែងពាលាផ្សេងៗនោះ ឱ្យវិលមករកផ្លូវល្អ និងភ្ញាក់រឭកចូលរៀនសូត្រវិញ ហើយចេះស្តាប់ដំបូន្មានឪពុកម្តាយលោកគ្រូ អ្នកគ្រូ ស្គាល់គុណ ស្គាល់ទោស ស្គាល់ល្អ ស្គាល់អាក្រក់ និងចេះគោរពចាស់ទុំ[15]។

---

[14] https://freshnewsasia.com/index.php/en/localnews/166624-2020-07-29-09-55-57.html

[15] https://kampongthom.gov.kh/7860/

## ឃ- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ក្នុងពិភពលោក

ផលប្រយោជន៍របស់ព្រះពុទ្ធសាសនាចំពោះពិភពលោកគឺមានច្រើនអនេក។ ដូចយើងបានរៀបរាប់មកខាងដើមហើយថា ព្រះពុទ្ធសាសនាមានតួនាទីប្រោសនិស្ស័យដល់យុវជនផង ប្រជាពលរដ្ឋផង និងចិញ្ចឹមមនុស្សក្រខ្សត់កម្សត់ទុគ៌តផង។

ព្រះពុទ្ធទ្រង់បានបញ្ញត្តិទុកមកថា «**អព្យាបជ្ឈំ សុខំ លោកេ**» បានន័យថា «**ការមិនបៀតបៀនគ្នាជាសុខក្នុងលោក**»។ ន័យត្រង់នេះមានន័យថា ការមិនបៀតបៀនគ្នា មិនចងពៀរវេរានឹងគ្នាជាមង្គលមួយដ៏ឧត្តមដែលប្រជាពុទ្ធបរិស័ទគប្បីប្រកាន់យក។ ជាពិសេសក្នុងន័យថា កាលណាយើងមិនបៀតបៀនគ្នានោះធ្វើឱ្យយើងចេះថែរក្សាសេចក្តីសុខរវាងគ្នានឹងគ្នា ហើយប្រកបទៅដោយសាមគ្គីធម៌ផង។ ប្រសិនបើជាតិសាសន៍ទាំងអស់នៅលើលោកយើងនេះ ចេះគោរពគ្នា ឱ្យតម្លៃគ្នា និងមានមេត្តាដល់គ្នានឹងគ្នា នោះសង្គមជាតិទាំងមូលច្បាស់ជាទទួលបាននូវសន្តិភាព។ ដូចនេះ ការមិនបៀតបៀនគ្នាជាសេចក្តីសុខដ៏ក្រៃលែងដែលមនុស្សទាំងអស់គប្បីបំពេញក្នុងនាមជាមនុស្សជាតិដូចគ្នា។ ការមិនបៀតបៀន ការមិនព្យាបាទ ការមិនឈ្នានីស ការមិនបំពាន ការមិនបង្កក្តីឈឺចាប់ដល់អ្នកដទៃគឺជាសីលធម៌ដ៏ខ្ពង់ខ្ពស់របស់មនុស្ស។ ការមិនធ្វើអំពើទាំងនេះលើអ្នកដទៃគឺជាហេតុដែលនាំឱ្យសង្គមមានសុខុដុមរមនា [16] ។ នេះជាគោលធម៌ដ៏អស្ចារ្យដែលព្រះពុទ្ធសាសនាបានសាបព្រោះនូវវប្បធម៌សន្តិភាពដល់មនុស្សជាតិ។

## ខ- ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ក្នុងសង្គមខ្មែរ

ជាការពិតណាស់ ព្រះពុទ្ធសាសនាបានជួយលើកម្ពស់ដល់ការអប់រំចរិយាសាស្រ្តដល់កូនខ្មែរសមណសិស្សឱ្យទទួលបានឱកាសរៀនសូត្រចំណេះដឹងទូទៅនៅតាមសាលាពុទ្ធិកបឋមសិក្សានានានៅក្នុងវត្តអារាមទូទាំងប្រទេស។ យើងបានកត់សម្គាល់ឃើញថា នៅតាមវត្តអារាមបានបំពេញតួនាទីដ៏អស្ចារ្យ គឺបានចិញ្ចឹមព្រះសង្ឃដែលជាកូនចៅអ្នកស្រុកបានមកស្នាក់នៅផង និងបួសរៀនក្នុងសម្នាក់ព្រះពុទ្ធសាសនាផងដែរ។

ក្នុងនោះយើងបានឃើញថា វត្តអារាមព្រះពុទ្ធសាសនាបានជួយសង្គ្រោះកុមារកំព្រាគ្មានទីពឹងឱ្យមានឱកាសសិក្សារៀនសូត្រចំណេះអក្សរសាស្រ្ត និងគណិតសាស្រ្តពីសម្នាក់គ្រូអាចារ្យរបស់ខ្លួន។ វត្តអារាមជាកន្លែងធានារ៉ាប់រងអាយុជីវិតដល់កូនចៅអ្នកស្រុកស្រែជនបទចុងកាត់មាត់ញក មនុស្សអនាថា

[16] https://thmeythmey.com/?page=detail&id=103655

ដែលគ្មានទីពឹងកម្សត់ទុគ៌តឱ្យមករស់នៅ ឬបួសរៀនបន្តការសិក្សាក្រោមម្លប់ព្រះពុទ្ធសាសនា។ វត្តអារាមបានជួយបណ្តុះបណ្តាលធនធានមនុស្សសម្រាប់រយៈពេលវែងដើម្បីជួយខ្លួនឯង គ្រួសារ និងសង្គមជាតិទៅថ្ងៃខាងមុខឱ្យកាន់តែមានភាពជឿនលឿន និងរីកដុះដាល។ វត្តអារាមនេះហើយជាផ្ទះទីពីរបន្ទាប់ពីផ្ទះនៅភូមិស្រុករៀងៗខ្លួនរបស់សមណសង្ឃ ឬកូនចៅអ្នកស្រុកដែលក្រខ្សត់លំបាកគ្មានទីពឹងពាក់ពំនាក់អាស្រ័យ។ បន្ថែមពីនេះវត្តអារាមជួយបង្កើតក្តីសង្ឃឹមឱ្យសមណសង្ឃ សិស្ស និស្សិតមានឱកាសសិក្សាផ្នែកខាងពុទ្ធចក្រផង និងអាណាចក្រផងដែលជាកង់រទេះពីរមិនអាចកាត់ផ្តាច់ពីគ្នាបាន។ វត្តអារាមជាមូលដ្ឋានដ៏រឹងមាំ ជាជានាវ៉ាប់រងអាយុជីវិតសម្រាប់កុមារដែលទីទ័លក្រលំបាកកម្សត់អត់ឃ្លាន ឱ្យមានឱកាសបានហូបចុកគ្រប់គ្រាន់ និងមានស្នាមញញឹមនៅក្នុងជីវិត។ ជាក់ស្តែងនៅពេលដែលសិស្សខ្លះដែលសាលារៀននៅឆ្ងាយ គេបានមកសុំស្នាក់អាស្រ័យនៅវត្តអារាមដើម្បីបន្តការសិក្សានៅវិទ្យាល័យ ឬមហាវិទ្យាល័យជាដើម។ ជាពិសេសនៅតាមស្រុកស្រែជនបទដែលសាលានៅឆ្ងាយ សិស្សតែងតែមកសុំព្រះគ្រូចៅអធិការមកស្នាក់អាស្រ័យ ហើយមានការយល់ព្រមពីអាចារ្យគណៈកម្មការផងដោយតម្រូវឱ្យសិស្ស ឬនិស្សិតទាំងអស់នោះបំពេញប្រវត្តិរូបសង្ខេប និងមានហត្ថលេខាពីមេឃុំផងដែលជាតឹកតាងយ៉ាងច្បាស់ថា យើងពិតជាអ្នកស្រុកដែលរស់នៅភូមិឃុំស្រុកនោះខេត្តនោះប្រាកដមែន។ នៅពេលដែលបានស្នាក់អាស្រ័យនៅតាមកុដិរៀងៗខ្លួនហើយ នៅក្នុងកុដិមានវិន័យកុដិដោយព្រះសង្ឃបានចែងជាវេនសម្អាត វេនថ្វាយបង្គំព្រះ និងវេនធ្វើចង្ហាន់ប្រគេនព្រះសង្ឃជាដើម។ ការសូត្រធម៌ថ្វាយបង្គំព្រះជាការបណ្តុះចរិយាធម៌ដ៏ប្រពៃឱ្យយើងយល់ដឹងពីធម៌អាថ៌ និងមានគំនិតគិតគូរដល់ព្រះធម៌ថ្លៃ ហើយដក់ជិតនៅក្នុងអារម្មណ៍នៃបុគ្គលម្នាក់ៗ។ ជាពិសេសឱ្យបុគ្គលម្នាក់ៗមានការភ្ញាក់រឭកដឹងប្រកបដោយយោនិសោមនសិការនៅក្នុងចិត្តសន្តានរបស់ខ្លួន។ ន័យនៅត្រង់នេះ យើងអាចទាញជាការសន្និដ្ឋានបានថា ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំចរិយាធម៌ដល់បុគ្គលទូទៅមិនមានការរើសអើងឡើយ។ ពោលគឺព្រះពុទ្ធសាសនាបានលើកកម្ពស់ដល់សមណសិស្ស សមណនិស្សិត សិស្ស និស្សិត ឱ្យហាត់ពត់លត់ដំបន្ទុំនិស្ស័យស្របទៅតាមមាគ៌ាព្រះពុទ្ធសាសនា។

ទ្រឹស្តីគោលសំខាន់ៗសុទ្ធសឹងតែជាវិធីដឹកនាំខ្សែជីវិតឆ្ពោះទៅរកភាពជឿនលឿន និងបង្កើតបានជាអនុស្សាវរីយ៍ជីវិតមិនអាចបំភ្លេចបាន។

## II.៣.៣- សំយោគតួនាទីព្រះពុទ្ធសាសនាក្នុងការអប់រំសីលធម៌ និងចរិយាធម៌

### ក. ការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌តាមរយៈការរក្សាសីល

សីលប្រាំ សីលប្រាំបី និងសីលដប់ជាកំពូលសីលដែលព្រះបរមសាស្តាចារ្យទូន្មានប្រៀនប្រដៅឱ្យបរិស័ទគោរពប្រតិបត្តិតរៀងទៅ។ ព្រះពុទ្ធអង្គជាកំពូលសាស្ត្រាចារ្យនៅលើលោក ហើយព្រះអង្គគ្មានគ្រូបាអាចារ្យណាប្រដៅព្រះអង្គឡើយ។

នៅក្នុងសង្គមខ្មែរ យើងបានឃើញថា ប្រជាជនបាននាំគ្នារក្សាសីល សមាធិ បញ្ញា ដោយនាំគ្នាទៅធ្វើបុណ្យនៅវត្តវ៉ានៅវត្តអារាមដើម្បីសម្អាតចិត្តឱ្យផូរផង់។ ន័យត្រង់នេះសបញ្ជាក់ថា ព្រះពុទ្ធសាសនាបានជួយតម្រង់ចិត្តបរិស័ទឱ្យស្អាតផូរផង់ មានសតិបញ្ញា និងប្រកបដោយសេចក្តីសុខ។ ប្រការមួយទៀត យើងបានឃើញថា ប្រជាជនដែលកាន់យកសីលប្រាំចាំសីលប្រាំបី នាំចិត្តគេបានក្តីសុខ មិនប្រព្រឹត្តខុសច្បាប់សង្គមដោយការមិនសេពសុរា មិនប្រព្រឹត្តខុសក្នុងផ្លូវកាមជាដើម។ ការបំពេញសីលបារមីនាំឱ្យបុគ្គលបានសេចក្តីសុខនិងប្រកបដោយចិត្តជ្រះថ្លាមានមេត្តាបារមី មានធម៌សន្តោសចិត្តសុចរិតទៀងត្រង់។ ព្រះពុទ្ធសាសនាទូន្មានឱ្យមនុស្សប្រកាន់យកសន្តិភាព គ្មានហិង្សា គ្មានសង្គ្រាមដោយអប់រំមនុស្សឱ្យពឹងលើខ្លួនឯងជឿជាក់លើសមត្ថភាពខ្លួនឯង។ ត្រៃសរណគមន៍ពុទ្ធសាសនាគឺព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ឯសង្គមមានបច្ច័យបីគឺបុគ្គល សង្គម និងធម្មជាតិដែលមានទំនាក់ទំនងជួយគ្នាទៅវិញទៅមកដើម្បីថែរក្សាពុទ្ធសាសនាក៏ដូចជាថែរក្សាសង្គមខ្មែរ។ លើសពីនេះ ព្រះពុទ្ធសាសនាបានចូលរួមក្នុងសង្គមខ្មែរក្នុងភាពជាអ្នកដឹកនាំប្រកបដោយទសពិធរាជធម៌ និងអប់រំបុគ្គល គ្រួសារលើផ្នែកចរិយាសាស្ត្រ សីលធម៌ សុជីវធម៌ គុណធម៌ និងចរិយាធម៌ជាដើម។

ការដើរតាមមាគ៌ាព្រះពុទ្ធសាសនានាំឱ្យយើងទទួលបាននូវពុទ្ធពរ៤ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ។ មានអាយុបានន័យថា មានអាយុវែង មានសុខភាពល្អ បរិបូណ៌ដោយគុណតម្លៃគ្រប់ប្រការ។ បានសុខៈ បានន័យថា មាននូវសេចក្តីសុខគ្រប់ប្រការ សុភមង្គល និងមានសេចក្តីស្ងប់ស្ងាត់ផ្លូវចិត្ត។ ពលៈ បានន័យថាបរិបូណ៌ដោយកម្លាំងកាយមាំមួន មាននូវភាពរឹងប៉ឹងផ្នែកប្រាជ្ញាស្មារតី។ ពុទ្ធពរនេះជាទ្រព្យដ៏វិសេសវិសាលភាពក្រៃលែងដែលពុទ្ធសាសនិកទទួលបាន កាលណាគេប្រតិបត្តិត្រឹមត្រូវតាមមាគ៌ាព្រះសាស្តា។ ផ្ទុយមកវិញ បើកាលណាគេមិនបានដើរតាមឱ្យបានខ្ជាប់ខ្ជួនទៅតាមនោះទេ នោះនាំឱ្យជីវិតជួបភាពអប្រិយ ពុំប្រពៃឡើយ។ ជាក់ស្តែងណាស់ បើមនុស្សមានសេចក្តីប្រមាទនៅក្នុងខ្លួននាំឱ្យជីវិតជួបតែ

សេចក្តីទុក្ខទោស មានភាពហ្មងសៅ និងមានបញ្ហាជីវិតមិនចេះចប់មិនចេះហើយ។ បើយើងក្រឡេកមកមើលតាមរយៈស្នាដៃអក្សរសិល្ប៍រឿងទុំទាវ អរជូនម៉ឺនងួនដែលប្រព្រឹត្តអំពើប្រាសចាកពីសីល ទីបំផុតត្រូវវិនាសអន្តរាយទាំងពូជអម្បូរ។ អរជូនបានប្រព្រឹត្តបាបធម៌គឺកាប់សម្លាប់ជីវិតទុំ ទើបកម្មពៀរវេរាតាមមកផ្តន្ទាទោសបែបនេះនាំឱ្យជួបតែសេចក្តីទុក្ខលំបាកវេទនាពន់ពេកក្រៃ។ នៅក្នុងរឿងរាមកេរ្តិ៍វិញ ក្រុងរាពណ៍ឆាប់ឆក់យកនាងសីតា ជាទង្វើទ្រុស្តនឹងធម៌កាមេ លួចយកអគ្គមហេសីរបស់ព្រះរាម ទើបត្រូវបានព្រះរាមតយុទ្ធធ្វើសង្គ្រាមវិញរហូតដល់រលាយក្រុងលង្កាទ្វីប។ នេះជាការបំពានសីល នាំជីវិតជួបតែសេចក្តីវិនាស។

សរុបមក ព្រះពុទ្ធសាសនាមានតួនាទីលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌តាមរយៈការរក្សាសីលប្រាំ សីលប្រាំបី និងសីលដប់ដែលជាមាគ៌ាមួយដ៏ថ្លៃថ្លាក្នុងការរស់នៅសមជាមនុស្សល្អ ជាពលរដ្ឋល្អ ជាពលរដ្ឋសាកលគ្រប់សម័យកាល។

## ខ-ការលើកកម្ពស់ការអប់រំសីលធម៌ ចរិយាធម៌ តាមរយៈការវៀរចាកអគតិធម៌

លើលោកនេះទំនងជាគ្មានបុគ្គលណាម្នាក់អាចលះដាច់ស្រឡះនូវអគតិនោះទេ។ អគតិទាំងបួននេះបើណាមួយស្ថិតនៅក្នុងចិត្តបុគ្គលពិសេសអ្នកដឹកនាំអង្គភាព ឬស្ថាប័នប្រាកដហើយ បុគ្គលិកក្រោមឱវាទច្បាស់ជាខូចសាមគ្គីភាព។

ព្រះសម្មាសម្ពុទ្ធបានអប់រំមនុស្សជាតិទាំងមូលឱ្យវៀរចាកនូវអគតិធម៌ទាំងបួនយ៉ាងឱ្យបានដាច់ស្រឡះជាដាច់ខាត។ លក្ខណៈនៃអគតិធម៌ទាំង៤យ៉ាងនោះរួមមានៈ

១-**ឆន្ទាគតិ** លម្អៀងព្រោះស្រឡាញ់ ដោយសារតែការស្រឡាញ់បើទោះជាទង្វើខុសឆ្គងយ៉ាងណា ការងារធ្វើមិនត្រូវយ៉ាងណា មិនលុះក្នុងការអប់រំយ៉ាងណាក៏នៅតែល្អ នៅតែស្រឡាញ់ពេញចិត្តរហូត។

២-**ទោសាគតិ** លម្អៀងព្រោះស្អប់ បើទោះជាបុគ្គលនោះប្រឹងប្រែងធ្វើការយ៉ាងណា ព្យាយាមស៊ូទ្រាំនឹងសម្ពាធផ្សេងៗកម្រិតណាក៏គ្មានន័យអ្វីដែរ ព្រោះចិត្តដែលគ្រាំដោយការស្អប់គឺនៅតែស្អប់ដដែល។

៣-**មោហាគតិ** លម្អៀងព្រោះល្ងង់ ដោយសារតែមិនសូវយល់ការណ៍ក៏ចេះតែយល់ព្រម ចេះតែបញ្ជូនដោយមិនខ្វល់ពីកើតមានវិបត្តិនៅពេលក្រោយទេ។

៤-**ភយាគតិ** លម្អៀងព្រោះខ្លាចគឺខ្លាចចំពោះរឿងដែលមិនគួរខ្លាចដូចជាខ្លាចបុគ្គលនោះជាកូនចៅអ្នកធំ បុគ្គលនោះជាអ្នកមានទ្រព្យ បើទោះជាធ្វើក្តី មិនធ្វើក្តី ប្រទើសបើសក្តីពុំហ៊ានស្តីបន្ទោសឱ្យទេចេះតែទ្រាំទៅ។

អគតិទាំង៤យ៉ាងនេះមិនគួរប្រព្រឹត្តឡើយ។ បើបុគ្គលអ្នកប្រព្រឹត្តយកការស្រឡាញ់ ស្អប់ ល្ងង់ ខ្លាចមកជាត្រីមុខយ៉ាងនេះហើយរមែងខូចយុត្តិធម៌ជាការមិនល្អទាំងអស់។ ហេតុនេះគួរលះបង់ចោលមិនគួរប្រព្រឹត្តទេ[17]។

សរុបមក ព្រះពុទ្ធសាសនាមានតួនាទីក្នុងការអប់រំវិជ្ជាសម្បទា បំណិនសម្បទា និងចរិយាសម្បទាដល់មនុស្សជាតិដោយមិនមានការរើសអើង។ ព្រះពុទ្ធសាសនាបានចូលរួមក្នុងជីវភាពមនុស្សខ្មែរតាំងពីដើមរៀងមករហូតមកដល់បច្ចុប្បន្ន និងបានកសាងមូលដ្ឋានអត្តសញ្ញាណទឹកដី អត្តសញ្ញាណវប្បធម៌ខ្មែរឱ្យមានកិត្តិយសមានឈ្មោះសមជាប្រជាជាតិដែលមានអរិយធម៌ និងជាម្ចាស់សុវណ្ណភូមិ។

## គ- ការប្រកាន់យកព្រហ្មវិហារធម៌ និងទសពិធរាជធម៌ជាគោល

ព្រហ្មវិហារធម៌បានដល់ធម៌ជាគ្រឿងស្ថិតនៅដ៏ប្រសើរ ធម៌ប្រចាំចិត្តដ៏ប្រសើរ គោលការណ៍ប្រព្រឹត្តដ៏បរិសុទ្ធ ធម៌ដែលត្រូវមានទុកជាគោលនៅក្នុងចិត្ត និងកាន់កាប់ការប្រព្រឹត្ត ទើបនឹងមាននាមថាដំណើរជីវិតហ្មត់ចត់ និងការប្រតិបត្តិខ្លួនចំពោះមនុស្សសត្វទាំងឡាយដូចជា[18]៖

**១. មេត្តា** សេចក្តីស្រឡាញ់ ប្រាថ្នាចង់ឱ្យមនុស្សគ្រប់រូបទទួលបានសេចក្តីសុខ។ សេចក្តីស្រឡាញ់ប្រាថ្នាល្អចង់ឱ្យគេមានសេចក្តីសុខ មានចិត្តមេត្រី និងគិតធ្វើប្រយោជន៍ដល់មនុស្សសត្វទូទៅ ។

**២. ករុណា** សេចក្តីអាណិត អាសូរចំពោះមនុស្សគ្រប់រូបពេលពួកគេមានទុក្ខ ដោយប្រាថ្នាចង់ឱ្យពួកគេធាប់រួចចាកសេចក្តីទុក្ខនោះ។ សេចក្តីអាណិតជួយឱ្យរួចផុតទុក្ខជួយសង្គ្រោះបំបាត់ទុក្ខលំបាករបស់ពពួកសត្វទាំងឡាយទាំងពួង។

[17] https://kohsantepheapdaily.com.kh/article/164456.html
18 https://km.wikipedia.org/wiki

**៣. មុទិតា** សេចក្តីរីករាយត្រេកអរ នៅពេលឃើញមនុស្សទាំងឡាយបានទទួលសេចក្តីសុខចម្រើន មានសេចក្តីត្រេកអរពេលឃើញអ្នកដទៃមានសេចក្តីសុខ មានចិត្តរីករាយសប្បាយជានិច្ចចំពោះសព្វសត្វទាំងឡាយនៅក្នុងលោកសន្និវាសនេះ។

**៤. ឧបេក្ខា** ការតាំងសន្តានចិត្តជាកណ្តាល (មិនលម្អៀង) កាត់សេចក្តីដោយប្រើប្រាជ្ញា ការតម្កល់ចិត្តជាកណ្តាលដែលនឹងធ្វើឱ្យតម្រង់នៅក្នុងធម៌តាមការពិចារណាឃើញដោយបញ្ញាគឺមានចិត្តរាបត្រង់ដោយធម៌ដូចជាជញ្ជីង មិនលម្អៀងដោយសេចក្តីស្រឡាញ់ ឬស្អប់ជាដើម។

នៅក្នុងសង្គមជាក់ស្តែង ប្រសិនបើបុគ្គលប្រកាន់យកនូវព្រហ្មវិហារធម៌ជាគោល នោះសង្គមទាំងមូលនឹងបានសេចក្តីសុខខ្លាំងណាស់។ រីឯគោលធម៌ទាំង១០នេះសម្រាប់អ្នកគ្រប់គ្រងជាតិ ឬព្រះមហាក្សត្រប្រកាន់យកដោយសុទ្ធចិត្តដើម្បីប្រតិបត្តិឱ្យបានសមជាអ្នកទ្រទ្រង់នូវភាពជាអ្នកដឹកនាំប្រទេសឈានឆ្ពោះទៅរកសេចក្តីសុខសេចក្តីចម្រើនរុងរឿងសុខសន្តិភាពជូនជាតិមាតុភូមិ។ ធម៌ទាំង១០ប្រការនេះគឺ[19]៖

១- **ទានៈ** ការឱ្យគឺការលះបង់ទ្រព្យសម្បត្តិ

២- **សីលៈ** ការប្រព្រឹត្តល្អគឺសង្រួមកាយវាចាចិត្តល្អហើយ

៣- **ចាគៈ** ការបរិច្ចាគគឺការលះបង់សេចក្តីសុខរបស់ខ្លួនដើម្បីប្រជារាស្ត្រ

៤- **អាជ្ជវៈ** ភាពទៀងត្រង់គឺមានមារយាទស្មោះត្រង់

៥- **មទ្ទវៈ** ភាពទន់ភ្លន់គឺមានអធ្យាស្រ័យទន់ភ្លន់ មិនរឹងត្អឹង មានៈ

៦- **តបៈ** ទ្រង់មានតេជៈគឺដុតកម្ទេចកិលេសតណ្ហា

៧- **អក្កោធៈ** ការមិនក្រោធគឺមិនក្រេវក្រោធមិនលុះក្នុងអំណាចនៃសេចក្តីក្រោធ

៨- **អវិហិង្សា** ការមិនបៀតបៀន

៩- **ខន្តិ** ការអត់ធន់គឺអត់ធន់ចំពោះការលំបាក

[19] https://kohsantepheapdaily.com.kh/article/1005385.html

១០- **អវិរោធនៈ** ការមិនឃ្លាតចាកធម៌ ។

គុណធម៌ទាំង១០ប្រការនេះជាគ្រឹះដែលព្រះរាជា ឬមេដឹកនាំគួរប្រកាន់យកដើម្បីសេចក្តីសុខ សេចក្តីចម្រើនរបស់ពលរដ្ឋ។

## ឃ- ការប្រកាន់យកមជ្ឈិមប្បដិបទា ឬផ្លូវកណ្តាលជាគោល

មគ្គអរិយសច្ចៈ វិធីរំលត់ទុក្ខប្រកបដោយមគ្គ (ត្រូវ) មាន ៨យ៉ាងគឺ (ហៅថា អដ្ឋង្គិកមគ្គ)។ មាគ៌ានាំទៅកាន់ការរំលត់ទុក្ខពិតប្រាកដ ការយល់ដឹងនូវមគ្គៈតែប៉ុណ្ណោះមិនគ្រប់គ្រាន់ទេ គេត្រូវខិតខំដើរតាមមាគ៌ានេះ និងប្រតិបត្តិតាមដោយទៀងទាត់ទៀត[20]។ មាគ៌ាទាំងប្រាំបីនោះមាន៖

- **សម្មាទិដ្ឋិ** : យល់ឃើញត្រូវ
- **សម្មាសង្កប្បៈ** : ត្រិះរិះត្រូវ
- **សម្មាវាចា** : សម្តីត្រូវ
- **សម្មាកម្មន្ត** : ការងារត្រូវ
- **សម្មាអាជីវៈ** : ការចិញ្ចឹមជីវិតត្រូវ
- **សម្មាវាយាម** : ព្យាយាមត្រូវ
- **សម្មាសតិ** : រឭកត្រូវ
- **សម្មាសមាធិ** : តាំងចិត្តត្រូវ

ព្រះពុទ្ធអង្គបានប្រដៅទូន្មានជនានុជនទាំងឡាយឱ្យប្រកាន់ខ្ជាប់នូវអដ្ឋង្គិកមគ្គ ឬមាគ៌ារំដោះទុក្ខទាំងប្រាំបីយ៉ាងនេះ ដោយដើរផ្លូវកណ្តាល ចេះល្មមព្រមជានិច្ច កុំបីប្រកាន់លោភៈ ទោសៈ មោហៈដែលនាំជីវិតឱ្យជួបតែសេចក្តីទុក្ខ។

## II.៤- សរុបខ្លឹមសារ

ព្រះពុទ្ធសាសនាបានរួមរស់រួមសុខរួមទុក្ខជាមួយនឹងសង្គមខ្មែរយ៉ាងជ្រាលជ្រៅជាទីបំផុតតាមរយៈអំណាចគុណធម៌ដ៏ឧត្តម។ ព្រះពុទ្ធអង្គបានប្រដៅណែនាំបុគ្គល គ្រួសារ និងសង្គមជាតិទាំងមូលឱ្យប្រកាន់

[20] រៀបរៀងនិងកែសម្រួលពីសៀវភៅអរិយធម៌ខ្មែររបស់អ្នកស្រី ត្រឹង ងា, គ.ស.១៩៧៤ ព.ស.២៥១៨ ទំព័រ២៥-៣៣

យកធម៌អហិង្សាជាគោលក្នុងការដោះស្រាយបញ្ហានានានៅក្នុងជីវិត។ ព្រះពុទ្ធសាសនាបានចារឹកជាប់នៅក្នុងដួងចិត្តមនុស្សខ្មែរ រួមរស់ក្នុងជីវភាពមនុស្សខ្មែររាប់សិបជំនាន់មកហើយ។ ជាពិសេសព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរប្រៀបបានដូចជាឱសថសម្រាប់ព្យាបាលរោគអវិជ្ជាផង និងបណ្តុះពន្លឺប្រាជ្ញាផង។ សាសនានេះបានជួយលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌ក្នុងសង្គមខ្មែរតាំងពីបុរាណកាលរហូតមកដល់សម័យសព្វថ្ងៃ។ ដើម្បីចូលរួមលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌នៅក្នុងសង្គមខ្មែរ ព្រះពុទ្ធសាសនាបានអប់រំតាមរយៈព្រះធម្មទេសនានៅតាមសាលារៀន អង្គភាព ស្ថាប័នដោយផ្ទាល់ក្តី និងតាមឌីជីថលក្តី ឬតាមបណ្តាញសង្គម។ ព្រះធម្មទេសនាបានបណ្តុះទឹកចិត្តជ្រះថ្លា មានចិត្តសាងបុណ្យកុសល និងហាត់ពត់លត់ដំស្មារតីបន្ទុំនិស្ស័យតាមសីល៥ ចាំសីល៨ និងសីល១០ជាដើម។ ព្រះពុទ្ធអង្គទូន្មានបុគ្គលឱ្យសាងសីលសុចរិត ប្រកាន់យកផ្លូវកណ្តាលជាគោលដើម្បីចិញ្ចឹមជីវិតទៅតាមសម្មាអាជីវៈ។ មេដឹកនាំដែលមានព្រហ្មវិហារធម៌ និងទសពិធរាជធម៌រមែងដឹកនាំឱ្យសង្គមជាតិជួបភាពសុខសាន្ត ហើយទទួលបាននូវការគោរពអាណិតស្រឡាញ់ពីអ្នកក្រោមបង្គាប់យ៉ាងជ្រាលជ្រៅ។

## III-**បញ្ចប់សេចក្តី**

ឆ្លងតាមការស្រាយបំភ្លឺ ប្រធានមានខ្លឹមសារល្អធ្វើឱ្យយើងយល់ដឹងជ្រួតជ្រាបពីតួនាទីព្រះពុទ្ធសាសនានៅក្នុងការលើកកម្ពស់ការអប់រំសីលធម៌ និងចរិយាធម៌សង្គមខ្មែរ។ ព្រះពុទ្ធសាសនាបានចូលរួមចំណែកអប់រំចិត្តគំនិត សតិអារម្មណ៍របស់មនុស្សគ្រប់ស្រទាប់វណ្ណៈប្រៀបបានដូចជាឱសថកែរោគដូច្នោះដែរ។ តាមរយៈទ្រឹស្តីគោលរបស់ព្រះពុទ្ធសាសនាបានញ៉ាំងឱ្យប្រជាពុទ្ធបរិស័ទកើតមានសេចក្តីជ្រះថ្លាខិតខំសន្សំបន្ទុំនិស្ស័យបុណ្យកុសលពីបច្ចុប្បន្នរហូតដល់អនាគតកាល។ ជាពិសេសឃ្លាំងពុទ្ធវចនៈបានជួយដុសខាត់ប្រាជ្ញាស្មារតីមនុស្សឱ្យកើតមានបញ្ញា មានសេចក្តីព្យាយាម និងរីកចម្រើនលូតលាស់ក្នុងជីវិតរបស់ខ្លួនស្របទៅតាមបរិបទនៃភូមិសាស្ត្រសង្គមវប្បធម៌ជាក់ស្តែង។ ដោយឡែកសព្វថ្ងៃនេះរឹងរឹតតែប្រសើរដែលក្រសួងអប់រំ យុវជន និងកីឡា អាចពិចារណាក្នុងការបញ្ចូលកម្មវិធីអប់រំតាមបែបព្រះពុទ្ធសាសនាចូលក្នុងកម្មវិធីសិក្សាដើម្បីឱ្យកូនខ្មែរក្តី យុវជនក្តីមានសញ្ញាណក្នុងការត្រេង់ត្រាប់សីលធម៌ និងគោលការណ៍ចរិយាធម៌តាមបែបព្រះពុទ្ធសាសនា។ ដូចនេះក្នុងនាមយើងជាពុទ្ធមាមិកជនគប្បីសិក្សាស្វែងយល់ឱ្យបានស៊ីជម្រៅនូវទ្រឹស្តីព្រះពុទ្ធសាសនា រួចប្រតិបត្តិប្រកបដោយការពិចារណាស្របដូចពុទ្ធភាសិតថែងថា «**នត្ថិ សន្តិ បរំ សុខំ**» ប្រែជាថា «**គ្មានសេចក្តីសុខឯណា ស្មើនឹងសេចក្តីស្ងប់ឡើយ**»។

## ឯកសារពិគ្រោះ


-«វចនានុក្រមខ្មែរភាគ១-២» ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ គ.ស. ១៩៦៧

- «វចនានុក្រមខ្មែរភាគ១-២» ការផ្សាយរបស់រាជបណ្ឌិត្យសភាកម្ពុជា ភ្នំពេញ គ.ស. ២០២៣

-លាងហាប់អាន, សិក្សាប្រវត្តិអក្សរសាស្ត្រខ្មែរ, សម័យនគរភ្នំដល់សម័យឧដុង្គ (សតវត្សទី១ ដល់ឆ្នាំ ១៨៥៩), ភ្នំពេញ, ឆ្នាំ ១៩៦៧

-លី ធាមតេង, អក្សរសាស្ត្រខ្មែរ, បណ្ណាគារ ងួន ហ៊ួត, ១៩៦០

-វង់ សុធារ៉ា, សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្ដាល, គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត, ២០១២

-សិក្សាស្នាដៃអក្សរសិល្ប៍ដោយបណ្ណាល័យ សេង សុវណ្ណារ៉ា, ២០២២

-ភាជ ណាង, និក្ខេបបទបណ្ឌិតអក្សរសាស្ត្រ ឯកទេសអក្សរសិល្ប៍ រាជបណ្ឌិត្យសភាកម្ពុជា ឆ្នាំ២០១៥

-អត្ថបទ៖ ថ្មគោលព្រះពុទ្ធសាសនា នៅសារមន្ទីរអង្គរបុរី ខេត្តតាកែវ

-ឥទ្ធិពលព្រះពុទ្ធសាសនាក្នុងសង្គមខ្មែរ, ដោយបណ្ឌិត ហែម ឡាច, មន្ត្រីនាយកដ្ឋាននីតិសាស្ត្រនៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសង្គម, រាជបណ្ឌិត្យសភាកម្ពុជា

-ប្រវត្តិសាស្ត្រនៃកម្ពុជា, វប្បធម៌ចេនឡា (ពីស.វ.ទី៦ ដល់ទី៨ នៃគ.ស.), បណ្ឌិត មីសែល ត្រាណេ, ភ្នំពេញ ព.ស.២៥៤៧ គ.ស. ២០០៣

-ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សទី១នៃគ្រិស្តសករាជរហូតមក, និពន្ធដោយលោកអាដេម៉ារ ឡឺក្លែរ អតីតរ៉េស៊ីដង់បារាំងប្រចាំប្រទេសកម្ពុជា, ប្រែសម្រួលដោយ ទេព ម៉េងឃាន ហៅ ទីឃាយុ, មជ្ឈមណ្ឌលឯកសារកម្ពុជា, បោះពុម្ពលើកទីមួយ ឆ្នាំ២០០៥

-ព្រះរាជបណ្ណាល័យកម្ពុជា, កម្ពុជសុរិយា សៀវភៅទស្សនាវដ្ដីចេញរាល់ខែ ពីព្រះរាជបណ្ណាល័យ ឆ្នាំគំរប់ ៧, ខ្សែ១,២,៣, រួមគ្នា, ព.ស.២៤៧៧ គ.ស. ១៩៣៥

-ខ្លូត ធីតា, «ព្រះពុទ្ធសាសនានិងការអភិវឌ្ឍសង្គមខ្មែរ» គ.ស. ១៩៩៦

-គួយ សូគាន, «អត្តសញ្ញាណវប្បធម៌ខ្មែរចូលរួមអភិវឌ្ឍសហគមន៍សេដ្ឋកិច្ច» ទស្សនាវដ្ដីសេដ្ឋកិច្ចខ្មែរ លេខទី៤០-៤៣ ខែមិថុនា-កញ្ញា ឆ្នាំ២០១៥

-មៀច ប៉ុណ្ណ, «តួនាទីនិងភារកិច្ចរបស់អាចារ្យ» ក្នុងសិក្ខាសាលាជាតិស្ដីពី «អាចារ្យក្នុងសង្គមខ្មែរបច្ចុប្បន្ន» រៀបចំដោយ រាជបណ្ឌិត្យសភាកម្ពុជា ថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១០

-អាង គឹមអៀង និង គី សុខលីម, «ព្រះបាទសម្ដេចព្រះ នរោត្តម សីហនុ ឥស្សរជនអមតៈ» រោងពុម្ពពន្លឺខ្មែរ គ.ស. ២០១៣

-អ្នកស្រី កែវ ណារុំ, «តន្ត្រីនិងជីវិតខ្មែរ» ការផ្សាយរបស់បណ្ណាល័យធពណ្ណរង្សី ២០១១

-អ្នកស្រី ត្រឹង ងា, «អរិយធម៌» ការផ្សាយរបស់អ្នកនិពន្ធ ១៩៧៥

-កម្រងស្នាដៃជ័យលាភីពានរង្វាន់អក្សរសិល្ប៍លើកទី៦ ទី៧ ទី៨ (ឆ្នាំ២០២១, ឆ្នាំ២០២២, ឆ្នាំ២០២៣)

-សីលធម៌ និងការអប់រំសីលធម៌នៅក្នុងវិទ្យាល័យមួយ, ង៉ែត ជឿន, ខែសីហា ឆ្នាំ២០១០

-អក្សរសាស្ត្រខ្មែរ ថ្នាក់ទី១១, គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ, បោះពុម្ពឆ្នាំ២០១៦

-បណ្ឌិត មីសែល ត្រាណេ, ប្រវត្តិសាស្ត្រនៃកម្ពុជា វប្បធម៌ ចេនឡា ពីស.វ. ទី៦ ដល់ទី៨នៃគ.ស. ទំ.១២០

-ឥន្ទបញ្ញោភិក្ខុ ហ. មណីចិន្តា, មគ្គុទ្ទេសក៍ជីវិត ឆ្នាំ១៩៩៧

-ដោយ៖ Ny Watthanak, ប្រភព៖ មីសែល ត្រាណេ, https://www.historiesKH/posts

- https://thmeythmey.com/?page=detail&id=28902

-https://www.678283688898073/1960391820687247

- https://www.rfi.fr/km/cambodia/buddhism-society

-https://ihss.rac.gov.kh/2020/03/04/%

-E. Aymonier, Le Cambodge, Tome III, 1904.

-https://www.khsearch.com/qna/15672

-https://km.wikipedia.org/wiki/%E%1

-https://rac.gov.kh/royal-academy/research/attachments/original/135.pdf?1625998633

-https://ihss.rac.gov.kh/2020/03/04/%

-https://foundation.wikimedia.org/wiki/Policy: Cookie_statement

-https://kohsantepheapdaily.com.kh/article/947824.html

-https://education4buddhist.wordpress.com/2015/08/11/

-https://freshnewsasia.com/index.php/en/freshnewsplus/163465-2020-06-25-12-37-12.html

- https://km.wikipedia.org/wiki/%E1%9E%

# ឧបសម្ព័ន្ធទី១

## ស្ថិតិវត្ត និងព្រះសង្ឃទូទាំងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣-២០២៤

ក្រសួងធម្មការ និងសាសនា
អគ្គនាយកកិច្ចការសាសនា
នាយកដ្ឋានកិច្ចការព្រះពុទ្ធសាសនា

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ស្ថិតិវត្ត និងព្រះសង្ឃទូទាំងព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០២៣-២០២៤**

| ល.រ | រាជធានី-ខេត្ត | ចំនួនវត្ត | | | ចំនួនព្រះសង្ឃ | ព្រះសង្ឃគណៈមហានិកាយ | | | ព្រះសង្ឃគណៈធម្មយុត្តិ | | | អាស្រម | មណ្ឌលវិបស្សនា |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | មហានិកាយ | ធម្មយុត្តិ | សរុប | ទាំងពីរគណៈ | ភិក្ខុ | សាមណេរ | សរុប | ភិក្ខុ | សាមណេរ | សរុប | | |
| 1 | បន្ទាយមានជ័យ | 243 | 12 | 255 | 4,243 | 1,242 | 2,880 | 4,122 | 34 | 87 | 121 | | |
| 2 | បាត់ដំបង | 368 | 15 | 383 | 6,116 | 1,780 | 4,059 | 5,839 | 54 | 223 | 277 | 12 | 2 |
| 3 | កំពង់ចាម | 366 | 12 | 378 | 5,639 | 1,326 | 4,169 | 5,495 | 26 | 118 | 144 | 16 | |
| 4 | កំពង់ឆ្នាំង | 215 | 4 | 219 | 2,600 | 719 | 1,825 | 2,544 | 4 | 52 | 56 | 14 | |
| 5 | កំពង់ស្ពឺ | 279 | 19 | 298 | 4,404 | 1,134 | 3,111 | 4,245 | 37 | 122 | 159 | 19 | |
| 6 | កំពង់ធំ | 288 | 4 | 292 | 3,295 | 831 | 2,440 | 3,271 | 5 | 19 | 24 | 23 | 5 |
| 7 | កំពត | 247 | 27 | 274 | 2,458 | 725 | 1,585 | 2,310 | 35 | 113 | 148 | | |
| 8 | កណ្ដាល | 327 | 32 | 359 | 6,900 | 1,657 | 4,769 | 6,426 | 89 | 385 | 474 | 7 | 5 |
| 9 | កោះកុង | 47 | 7 | 54 | 497 | 173 | 245 | 418 | 11 | 68 | 79 | | |
| 10 | ក្រចេះ | 167 | 13 | 180 | 1,422 | 379 | 956 | 1,335 | 15 | 72 | 87 | 2 | 4 |
| 11 | មណ្ឌលគិរី | 29 | 11 | 40 | 217 | 55 | 118 | 173 | 12 | 32 | 44 | | 1 |
| 12 | រាជធានីភ្នំពេញ | 142 | 9 | 151 | 8,445 | 3,317 | 5,005 | 8,322 | 48 | 75 | 123 | | |
| 13 | ព្រះវិហារ | 115 | 3 | 118 | 841 | 273 | 538 | 811 | 7 | 23 | 30 | 6 | 2 |
| 14 | ព្រៃវែង | 500 | 19 | 519 | 4,582 | 1,268 | 3,197 | 4,465 | 34 | 83 | 117 | | |
| 15 | ពោធិ៍សាត់ | 193 | 10 | 203 | 2,196 | 576 | 1,550 | 2,126 | 18 | 52 | 70 | | |
| 16 | រតនគិរី | 37 | 3 | 40 | 370 | 106 | 246 | 352 | 5 | 13 | 18 | | |
| 17 | សៀមរាប | 253 | 8 | 261 | 5,016 | 1,919 | 3,045 | 4,964 | 13 | 39 | 52 | 18 | 27 |
| 18 | ព្រះសីហនុ | 36 | 2 | 38 | 706 | 184 | 509 | 693 | 8 | 5 | 13 | 1 | 4 |
| 19 | ស្ទឹងត្រែង | 89 | 4 | 93 | 526 | 147 | 353 | 500 | 5 | 21 | 26 | 2 | 1 |
| 20 | ស្វាយរៀង | 245 | 1 | 246 | 2,253 | 937 | 1,315 | 2,252 | 1 | | 1 | | |
| 21 | តាកែវ | 320 | 27 | 347 | 4,392 | 1,132 | 3,057 | 4,189 | 53 | 150 | 203 | 10 | |
| 22 | ឧត្ដរមានជ័យ | 85 | 13 | 98 | 626 | 259 | 275 | 534 | 34 | 58 | 92 | | |
| 23 | កែប | 15 | 2 | 17 | 235 | 57 | 125 | 182 | 7 | 46 | 53 | | |
| 24 | ប៉ៃលិន | 28 | 6 | 34 | 427 | 91 | 263 | 354 | 8 | 65 | 73 | | 1 |
| 25 | ត្បូងឃ្មុំ | 240 | 9 | 249 | 2,773 | 725 | 2,012 | 2,737 | 10 | 26 | 36 | 6 | |
| | សរុប | 4,874 | 272 | 5,146 | 71,179 | 21,012 | 47,647 | 68,659 | 573 | 1,947 | 2,520 | 136 | 52 |

បានឃើញ និងឯកភាព
ថ្ងៃ... ខែ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមករា ឆ្នាំ២០២៤
**រដ្ឋមន្ត្រី**
ចាយ_បូរិន

បានឃើញ និងពិនិត្យត្រឹមត្រូវ
ថ្ងៃ... ១កើត ខែ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែមករា ឆ្នាំ២០២៤
**អគ្គនាយកកិច្ចការសាសនា**
ស៊ុន សុវណ្ណនិ

ថ្ងៃ... ខែ... ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែមករា ឆ្នាំ២០២៤
**ប្រធាននាយកដ្ឋាន**
គឹម_ជួប

# ឧបសម្ព័ន្ធទី២

«សិលាចារឹក គោកស្វាយចេក»



សំណៅផ្ដាមសិលាចារឹក គោកស្វាយចេក K 754/Ka 516 (ឯកសារសាលាបារាំងចុងបូព៌ា)

## ឧបសម្ព័ន្ធទី៣

សិលាចារឹក«សុវណ្ណភូមិ» ពីវត្តគិរីស្តេចគង់ ស្ថិតនៅឃុំស្វាយចចិប ស្រុកបរសេដ្ឋខេត្តកំពង់ស្ពឺ, ទៅតម្កល់រក្សាទុកនៅក្នុងសារមន្ទីរជាតិ រាជធានីភ្នំពេញ, ថ្ងៃសុក្រ ១៤កើត ខែមិគសិរ ឆ្នាំច សំរិទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨









# ឧបសម្ព័ន្ធទី៤

ព្រះពុទ្ធរូបព្រះភ័ក្ត្របួន និងព្រះបាទព្រះរាជាសម័យលង្វែក នៅវត្តត្រឡែងកែង

ភូមិសាស្ត្រអតីតរាជធានីលង្វែក, ថ្ងៃពុធ ទី១០ ខែមករា ឆ្នាំ២០២៤




# ឧបសម្ព័ន្ធទី៥

ប្រាសាទតុលាការ, ភូមិសាស្ត្រអតីតរាជធានីលង្វែក, ថ្ងៃពុធ ទី១០ ខែមករា ឆ្នាំ២០២៤



## ឧបសម្ព័ន្ធទី៦

កំពូលប្រាង្គ, ទីតាំងតម្កល់ព្រះបរមសិរីរិកធាតុនៃព្រះពុទ្ធពីអតីតកាល, ស្ថិតនៅក្នុងភូមិឧដុង្គ សង្កាត់រាំងចាស់ ក្រុងឧដុង្គម៉ែជ័យ ខេត្តកំពង់ស្ពឺ , ថ្ងៃពុធ ទី១០ ខែមករា ឆ្នាំ២០២៤

(ព្រះបរមសិរីរិកធាតុនៃព្រះសម្ពុទ្ធជាម្ចាស់ និងព្រះអរហន្តទៅតម្កល់ក្នុងទីវត្តប្រាង្គណ៍ (ឧដុង្គ) ខេត្តកំពង់ស្ពឺ ពីថ្ងៃ៩កើត ខែពិសាខ ឆ្នាំច ឆស័ក ព.ស.២៤៧៦ ត្រូវនឹងថ្ងៃ២២ អាវរិល ១៩៣៤ )





# ឧបសម្ព័ន្ធទី៧

ព្រះវិហារ និងកាំភ្លើងធំៗ សម័យព្រះអង្គឌួង ស្ថិតនៅក្នុងវត្តហរិរក្សរាជិនី (វាំងចាស់)

សង្កាត់វាំងចាស់ ក្រុងឧដុង្គម៉ែជ័យ ខេត្តកំពង់ស្ពឺ , ថ្ងៃពុធ ទី១០ ខែមករា ឆ្នាំ២០២៤



## ឧបសម្ព័ន្ធទី៨

### ព្រះពុទ្ធរូបប្រក់នាគ និងព្រះពុទ្ធបាទ






# ឧបសម្ព័ន្ធទី៩

## ទ្រឹស្តីបដិច្ចសមុប្បាទ

បដិច្ចសមុប្បាទ

**( Dependent Origination )**



# ឧបសម្ព័ន្ធទី១០

ភ្នំព្រះរាជទ្រព្យ ឬភ្នំអដ្ឋវិស្ស ឬភ្នំឧដុង្គ ( ទីតម្កល់ព្រះបរមសិរីរិកធាតុព្រះពុទ្ធសព្វថ្ងៃ )

